# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


១៨-១២-២០១៤ -ព្រះរាជក្រម នស/រកម/១០១៤/0២៦ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពី ហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១៥ ១១៩៤០


### ២~ព្រះរាជក្រឹត្យ


២៦-១១-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/១១១៤/១៣៩៥ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ឯក ជូននាយទាហាន ថ្នាក់ឧត្តមសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ចំនួន 0៣ រូប ១១៩៧២

២៦-១១-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/១១១៤/១៣៩៦ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជាករណីពិសេស ជូនមន្ត្រីរាជការ 0២ រូប នៅក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ១១៩៧៣

២៦-១១-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/១១១៤/១៣៩៧ ស្តីពី ការប្តូរ និងតម្លើងប្រភេទក្របខ័ណ្ឌ ជាករណីពិសេស ជូនលោកជំទាវ **ម៉ែន សំអុន** នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ១១៩៧៤

២៦-១១-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/១១១៤/១៣៩៨ ស្តីពី ការបញ្ចប់មុខតំណែង ឯកឧត្តម **លី ឈាវុន** ពីទីប្រឹក្សាឯកឧត្តមបណ្ឌិត **ងួន ញិល** អនុប្រធានទី ២ នៃរដ្ឋសភា មានឋានៈ ស្មើ រដ្ឋមន្ត្រី ដោយសាម៉ីខ្លួនសុំលាឈប់ ១១៩៧៥

28-11-2014 -KRET NS/KRT/1114/1399 NOMMONS *Son Exellence Madame Kethy Tioulong, Membre du Cabinet de Sa Majesté le Roi du Cambodge avec rang de Ministre d'Etat.* ១១៩៧៦

២៨-១១-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/១១១៤/១៤00 ស្តីពី ការតម្លើងឋានៈអ្នកអង្គម្ចាស់ក្សត្រី និងអ្នកអង្គម្ចាស់ ជាព្រះអង្គម្ចាស់ក្សត្រី និងជាព្រះអង្គម្ចាស់ ចំនួន ១២ ព្រះអង្គ ១១៩៧៧

២៨-១១-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/១១១៤/១៤0១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម អស់លោក ជាជនបរទេស ចំនួន 0៨ រូប ១១៩៧៨

២៨-១១-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/១១១៤/១៤0២ ស្តីពី ការដាក់ឯកឧត្តម **ឆា ជុំប** ឱ្យចូលនិវត្តន៍ ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ២ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួង បរិស្ថាន ១១៩៧៩

២៨-១១-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/១១១៤/១៤០៣ ស្តីពី ការប្តូរ និងតម្លើងប្រភេទក្របខ័ណ្ឌ ជាករណីពិសេស ជូនមន្ត្រីរាជការ ០៥ រូប របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ១១៩៨០
២៨-១១-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/១១១៤/១៤០៤ ស្តីពី ការតែងតាំង អគ្គលេខាធិការ-តែងតាំង និងផ្តល់ឋានៈ អគ្គលេខាធិការរង នៃគណៈវិស្វករកម្ពុជា សម្រាប់អាណត្តិទី ២ ចំនួន ០៧ រូប ១១៩៨២
២៨-១១-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/១១១៤/១៤០៥ ស្តីពី ការតែងតាំង ថ្នាក់ដឹកនាំគណៈកម្មាធិការជាតិអេស្កាប់ (គ.ជ.អ.ស) ចំនួន ០៣ រូប ១១៩៨៤

# II. រាជរដ្ឋាភិបាល

## ១. អនុក្រឹត្យ

១៧-១២-២០១៤ -អនុក្រឹត្យលេខ ៣២៤ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ១១៩៨៦
១៨-១២-២០១៤ -អនុក្រឹត្យលេខ ៣២៥ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ១១៩៨៨
០៧-១០-២០១៤ -អនុក្រឹត្យលេខ ១៤៧៦ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១១៩៩០
០៧-១០-២០១៤ -អនុក្រឹត្យលេខ ១៤៧៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១១៩៩១
០៩-១០-២០១៤ -អនុក្រឹត្យលេខ ១៤៧៨ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ១២០០១
០៩-១០-២០១៤ -អនុក្រឹត្យលេខ ១៤៧៩ អនក្រ.តត ស្តីពី ការធ្វើនិយ័តកម្មថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការ ១២០០២
០៩-១០-២០១៤ -អនុក្រឹត្យលេខ ១៤៨០ អនក្រ.តត ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ១២០០៤
០៩-១០-២០១៤ -អនុក្រឹត្យលេខ ១៤៨១ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជូនមន្ត្រីរាជការ ១២០០៥
០៩-១០-២០១៤ -អនុក្រឹត្យលេខ ១៤៨២ អនក្រ.តត ស្តីពី ការតម្លើងថ្នាក់មន្ត្រីរាជការ ១២០០៦
១០-១០-២០១៤ -អនុក្រឹត្យលេខ ១៤៨៣ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ១២០០៧
១០-១០-២០១៤ -អនុក្រឹត្យលេខ ១៤៨៤ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ១២០០៨
១០-១០-២០១៤ -អនុក្រឹត្យលេខ ១៤៨៥ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១២០១៧
១០-១០-២០១៤ -អនុក្រឹត្យលេខ ១៤៨៦ អនក្រ.តត ស្តីពី ការតែងតាំង និងសម្រួលភារកិច្ចជូនមន្ត្រីរាជការ ១២០៣១
១០-១០-២០១៤ -អនុក្រឹត្យលេខ ១៤៨៧ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១២០៣២
១០-១០-២០១៤ -អនុក្រឹត្យលេខ ១៤៨៨ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១២០៣៣
១៣-១០-២០១៤ -អនុក្រឹត្យលេខ ១៤៨៩ អនក្រ.តត ស្តីពី ការផ្ទេរបញ្ចូលទៅក្នុងមន្ត្រីក្រមការ និងទៅក្នុងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន ១២០៣៥
១៣-១០-២០១៤ -អនុក្រឹត្យលេខ ១៤៩០ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ១២០៣៧

១៣-១០-២០១៤ -អនុក្រឹត្យលេខ ១៤៩១ អនក្រ.តត ស្តីពី ការតម្លើងថ្នាក់ជូនមន្ត្រីរាជការ ១២០៤១

១៣-១០-២០១៤ -អនុក្រឹត្យលេខ ១៤៩២ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិជាកិច្ចបច្ឆាមរណៈ ១២០៤៨

## ២-សេចក្តីសម្រេច

១៨-១២-២០១៤ -សេចក្តីសម្រេចលេខ ១៦៥ សសរ ស្តីពី ការកែសម្រួល និងបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាល ទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ១២០៥០

១៨-១២-២០១៤ -សេចក្តីសម្រេចលេខ ១៦៦ សសរ ស្តីពី ការបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ១២០៥២

## III-ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

២១-១១-២០១៤ -ប្រកាសអន្តរក្រសួងលេខ ២១៤ ប្រក.ដនស ស្តីពី នីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ១២០៥៧

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម

១៦-១០-២០១៤ -ប្រកាសលេខ ០២៧៩ ឧស.កឧ.ប្រក.១០ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខេមបូឌានធីម វើក អ៊ិនដាសស្ត្រី បង្កើតរោងចក្រផលិត ស្បែកជើង ១២០៦៤

១៦-១០-២០១៤ -ប្រកាសលេខ ០២៨០ ឧស.កឧ.ប្រក.១០ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស្តារ ៨ អេស៊ា ភីធីវ៉ាយ អិលធីឌី បង្កើតរោងចក្រផលិត បន្ទះសូឡា ១២០៦៨

២៤-១០-២០១៤ -ប្រកាសលេខ ០២៩២ ឧស.កឧ.ប្រក.១០ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អ៊ីសាសស៊ុនអយហ្វៀល អេឃ្វីបម៉ិន មេនូហ្វេកធើរីង (ខេមបូឌា) បង្កើតរោងចក្រផលិត ដែកបំពង់ ១២០៧២

២៤-១០-២០១៤ -ប្រកាសលេខ ០២៩៣ ឧស.កឧ.ប្រក.១០ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ថិចភែកភែកឃិជីង (ខេមបូឌា) បង្កើតរោងចក្រផលិត សម្ភារៈវេចខ្ចប់ (ពីក្រដាស) និងសម្ភារៈវេចខ្ចប់ (ពីប្លាស្ទិក) ១២០៧៦

# ព្រះរាជក្រម

នស/រកម/១២១៤/០២៦

## យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
### សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
### ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
### ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៤ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ច្បាប់
# ស្តីពី
# ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង
# ឆ្នាំ ២០១៥

# ជំពូកទី ១
## ថវិកាថ្នាក់ជាតិ

**មាត្រា ១.-**

ត្រូវបានអនុញ្ញាតសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥ ឲ្យប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិ នូវពន្ធដារ វិភាគទាន អាករ ផលទុន និងចំណូលនានា ព្រមទាំងធ្វើឲ្យសម្រេចនូវឧបត្ថម្ភកធនវិនិយោគ និងការខ្ចីតាមមាតិកាថវិកា ដូចមានចែងក្នុងតារាង "ក" ដែលភ្ជាប់មកជាមួយច្បាប់នេះ ក្នុងទឹកប្រាក់សរុបចំនួន ១៥ ១៣៥ ២៣០ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណូលចរន្ត..........................................................១១ ០១៤ ៦៤៤ លានរៀល
- ចំណូលមូលធន.......................................................៤ ១២០ ៥៨៦ លានរៀល
  - \+ ចំណូលមូលធនក្នុងប្រទេស.......................................១៣៣ ៥៨៦ លានរៀល
  - \+ ចំណូលមូលធនក្រៅប្រទេស...................................៣ ៩៨៧ ០០០ លានរៀល
    - មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ ................................................................៣០០ ០០០ លានរៀល
    - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ..............................................................៣ ៦៨៧ ០០០ លានរៀល

**មាត្រា ២.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥ ត្រូវបានកំណត់ស្មើនឹង ១៥ ០៣៥ ២២៩ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណាយចរន្ត..........................................................៩ ២៧៥ ១៦១ លានរៀល
- ចំណាយមូលធន.......................................................៥ ៧៦០ ០៦៨ លានរៀល

ក-វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ....................................................................១ ៦៣៦ ៥០០ លានរៀល

- ដោយថវិកាថ្នាក់ជាតិ.......................................១ ៣៣៦ ៥០០ លានរៀល
  - ▪ គម្រោងវិនិយោគផ្ទាល់.......................១ ០១៩ ៧០០ លានរៀល

- បដិភាគក្នុងការអនុវត្តគម្រោងហិរញ្ញប្បទានក្រៅប្រទេស
  ........................................................៣១៦ ៨០០ លានរៀល

- ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ
  ....................................................................៣០០ ០០០ លានរៀល

ខ-វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

.......................................................................៣ ៦៨៧ ០០០ លានរៀល

គ- ការទូទាត់ការខ្ចី........................................................៤៣៦ ៥៦៨ លានរៀល

**មាត្រា ៣.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយចរន្តថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥ ត្រូវបានកំណត់ស្មើនឹង ៩ ២៧៥ ១៦១ លានរៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងទៅតាមប្រភេទចំណាយ ដូចមានចែងក្នុងតារាង "ខ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៤.-**

ចំនួនទឹកប្រាក់នៃឥណទានចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសសម្រាប់ការគ្រប់គ្រងពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៧ ត្រូវបានកំណត់ស្មើនឹង ១៥ ៣៨៧ ៩១២ លានរៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ តាមគម្រោង និងតាមឆ្នាំ ដូចមានចែងក្នុងតារាង "គ១" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៥.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យា និងឥណទានទូទាត់សម្រាប់ចំណាយមូលធនថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥ ត្រូវបានកំណត់ដូចខាងក្រោម ៖

- ឥណទានភ្ជាប់សន្យា..................................................៥ ៧៦០ ០៦៨ លានរៀល
- ឥណទានទូទាត់.........................................................៥ ៧៦០ ០៦៨ លានរៀល

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ឥណទាននេះត្រូវបានបែងចែកដូចតទៅ៖

ក. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

- ឥណទានភ្ជាប់សន្យា..................................១ ៦៣៦ ៥០០ លានរៀល
- ឥណទានទូទាត់........................................១ ៦៣៦ ៥០០ លានរៀល

ខ. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

- ឥណទានភ្ជាប់សន្យា..................................៣ ៦៨៧ ០០០ លានរៀល
- ឥណទានទូទាត់........................................៣ ៦៨៧ ០០០ លានរៀល

គ. ការទូទាត់ការខ្ចី

- ឥណទានភ្ជាប់សន្យា......................................៤៣៦ ៥៦៨ លានរៀល
- ឥណទានទូទាត់............................................៤៣៦ ៥៦៨ លានរៀល

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ ដូចមានចែងក្នុងតារាង "គ២" និង "ឃ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៦.-**

តុល្យភាពនៃថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥ ដែលបានរៀបចំនៅក្នុងតារាង "ក" ស្ដីពីចំណូលថវិកាថ្នាក់ជាតិ និងតារាង "ខ" ស្ដីពីចំណាយថវិកាថ្នាក់ជាតិ ត្រូវបានបង្ហាញនៅក្នុងតារាងកិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិដូចខាងក្រោម ៖

ឯកតា:លានរៀល

| កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ | ចំនួនទឹកប្រាក់ | តុល្យភាព/ហិរញ្ញប្បទាន |
|---|---|---|
| I. ចំណូលក្នុងប្រទេសសរុប | ១១ ១៤៨ ២៣០ | |
| ១. ចំណូលចរន្ត | ១១ ០១៤ ៦៤៤ | |
| ២. ចំណូលមូលធនក្នុងប្រទេស | ១៣៣ ៥៨៦ | |
| II. ចំណាយថវិកាសរុប | ១៤ ៥៩៨ ៦៦១ | |
| ១. ចំណាយចរន្ត | ៩ ២៧៥ ១៦១ | |
| ២. ចំណាយមូលធន (មិនគិតការទូទាត់ការខ្ចី) | ៥ ៣២៣ ៥០០ | |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ១ ៦៣៦ ៥០០ | |
| + ដោយថវិកាថ្នាក់ជាតិ | ១ ៣៣៦ ៥០០ | |
| - គម្រោងវិនិយោគផ្ទាល់ | ១ ០១៩ ៧០០ | |
| - បដិភាគ | ៣១៦ ៨០០ | |
| + ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទាន ដោយដៃគូអភិវឌ្ឍ | ៣០០ ០០០ | |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | ៣ ៦៨៧ ០០០ | |
| អតិរេកនៃថវិកាចរន្ត ( I.១ -II.១ ) | | +១ ៧៣៩ ៤៨៣ |
| ឱនភាពសរុបនៃថវិកាថ្នាក់ជាតិ (I-II ) | | -៣ ៤៥០ ៤៣១ |
| III. ហិរញ្ញប្បទាននៃឱនភាព | | +៣ ៤៥០ ៤៣១ |
| ១. ហិរញ្ញប្បទានក្រៅប្រទេស | | +៣ ៥៥០ ៤៣២ |
| • មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ | | +៣០០ ០០០ |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | | +៣ ៦៨៧ ០០០ |
| • ការទូទាត់ការខ្ចី | | -៤៣៦ ៥៦៨ |
| ២. ហិរញ្ញប្បទានក្នុងប្រទេស | | -១០០ ០០១ |
| • បញ្ញើរាជរដ្ឋាភិបាល | | -១០០ ០០១ |

ROYAUME DU CAMBODGE * LE MINISTERE DU PALAIS ROYAL

# ជំពូកទី ២

## ការខ្ចី និងការធានារបស់រដ្ឋ

**មាត្រា ៧.-**

សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥ អនុម័តយល់ព្រមឲ្យរាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេក្នុងកម្រិត ៦០០ ០០០ ០០០ SDR (ប្រាំមួយរយលានអេសដេអ៊ែរ) ។

ការខ្ចីដែលត្រូវចុះកិច្ចសន្យាក្នុងកម្រិតខាងលើ ត្រូវមានលក្ខណៈជាការខ្ចីសម្បទានដែលត្រូវសងវិញជាមួយការប្រាក់អនុគ្រោះ។

នៅក្នុងលក្ខខណ្ឌនេះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នកមានសិទ្ធិស្របច្បាប់តែមួយគត់ តាមការប្រទានសិទ្ធិជាលាយលក្ខណ៍អក្សររបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការចុះហត្ថលេខាលើការខ្ចី ជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋ ឬលើការធានារបស់រដ្ឋហើយត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តនៃការខ្ចី និងការធានានេះជូនរដ្ឋសភា និងព្រឹទ្ធសភារៀងរាល់ ៦ ខែម្តង ។

**មាត្រា ៨.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការឯកភាពពីធនាគារជាតិនៃកម្ពុជាត្រូវបានទទួលការអនុញ្ញាតឲ្យបោះផ្សាយបណ្ណរតនាគារ ក្នុងកម្រិតទឹកប្រាក់ដែលមានស្តុកចំនួន ១០០ ០០០ ០០០ ០០០ រៀល (មួយរយពាន់លានរៀល) ដើម្បីដោះស្រាយតម្រូវការជាបន្ទាន់ខាងសាច់ប្រាក់ ។ លក្ខខណ្ឌនៃការលក់បណ្ណរតនាគារនេះត្រូវកំណត់ដោយលិខិតបទដ្ឋានស្របច្បាប់ ។

**មាត្រា ៩.-**

សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥ អនុម័តយល់ព្រមឲ្យរាជរដ្ឋាភិបាលអនុញ្ញាតឲ្យអគ្គិសនីកម្ពុជាខ្ចីនូវទឹកប្រាក់ចំនួន ៣២ ៤០០ ០០០ ០០០ រៀល (សាមសិបពីរពាន់បួនរយលានរៀល) ។

**មាត្រា ១០.-**

មិនអនុញ្ញាតឲ្យក្រសួង ឬស្ថាប័នសាធារណៈណាមួយចំណុះរដ្ឋ មានសិទ្ធិចុះហត្ថលេខាក្រោមរូបភាពបោះផ្សាយមូលបត្ររយៈពេលវែង មធ្យម ខ្លី ឬឥណទានអ្នកផ្គត់ផ្គង់ ឬចុះកិច្ចសន្យាក្រោមរូបភាពទទួលបន្ទុកខ្ចី ឬការធានាកិច្ចសន្យាដែលបានចុះហត្ថលេខាដោយស្ថាប័នសាធារណៈ ឬឯកជន ឬចុះកិច្ចសន្យាក្រោមរូបភាពកិច្ចសន្យាផ្សេងៗទៀត ដែលត្រូវសងបំណុលតាមកាលកំណត់ ឬតាមឆ្នាំ ដែលស្ថិតនៅក្រៅវិសាលភាពនៃច្បាប់ហិរញ្ញវត្ថុ និងលក្ខខណ្ឌទាំងឡាយដែលច្បាប់នេះបានកំណត់នោះទេ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

# ជំពូកទី ៣

## បទប្បញ្ញត្តិស្តីពីពន្ធដារ

**មាត្រា ១១.-**

មាត្រា ៤៧ នៃច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈឆ្នាំ ១៩៩៧ ត្រូវបានកែប្រែដូចខាងក្រោម ៖

មាត្រា៤៧.-ថ្មី

សម្រាប់និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវបង់ ត្រូវកំណត់លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងត្រូវកាត់ទុកដោយនិយោជកតាមអត្រាកំណើនតាមថ្នាក់ ដូចតទៅ ៖

| ភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | ០៛ | ដល់ | ៨០០ ០០០៛ | ០% |
| ពី | ៨០០ ០០១៛ | ដល់ | ១ ២៥០ ០០០៛ | ៥% |
| ពី | ១ ២៥០ ០០១៛ | ដល់ | ៨ ៥០០ ០០០៛ | ១០% |
| ពី | ៨ ៥០០ ០០១៛ | ដល់ | ១២ ៥០០ ០០០៛ | ១៥% |
| | | លើសពី | ១២ ៥០០ ០០០៛ | ២០% |

**មាត្រា ១២.-**

មាត្រា ២៩ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ១១ន.ស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ត្រូវបានកែប្រែដូចខាងក្រោម ៖

មាត្រា ២៩.-ថ្មី

ពន្ធលើដីធ្លីមិនបានប្រើប្រាស់ត្រូវបង់ដោយកម្មសិទ្ធិករ ចំពោះដីដែលពុំមែនជាកម្មវត្ថុនៃពន្ធលើអចលនទ្រព្យ ។

**មាត្រា ១៣.-**

មន្ត្រីពន្ធដារទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ឲ្យពិនិត្យបទល្មើសលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដោយអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

ទម្រង់បែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីពន្ធដារ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

រាល់ប្រតិបត្តិការរបស់មន្ត្រីពន្ធដារក្នុងការពិនិត្យ និងការស៊ើបអង្កេតបទល្មើសលើបទប្បញ្ញត្តិស្តីពីពន្ធដារត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ អគ្គនាយកដ្ឋានពន្ធដារមានសិទ្ធិស្នើសុំកិច្ចសហការពីស្ថាប័នមានសមត្ថកិច្ច ដើម្បីចូលរួមបង្ក្រាបបទល្មើសលើបទប្បញ្ញត្តិស្តីពីពន្ធដារ ។

## ជំពូកទី ៤

## និយ័តភាពឡូបនីយកម្មនៃកិច្ចប្រតិបត្តិការ ចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤

### មាត្រា ១៤.-

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ៦១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ត្រូវបានយល់ព្រមជាគោលការណ៍ផ្តល់ឥណទានថវិកាបន្ថែមដល់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ ចំនួនទឹកប្រាក់ ២៧៦ ៥០០ ០០០ ០០០ រៀល (ពីររយចិតសិបប្រាំមួយពាន់ប្រាំរយលានរៀលគត់) សម្រាប់ទូទាត់ជម្រះបុរេប្រទានចាប់ពីឆ្នាំ ២០០៤ ដល់ ឆ្នាំ ២០១៤ ។

ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ នឹងអនុម័តនូវចំនួនទឹកប្រាក់ជាក់ស្តែងនៃកិច្ចប្រតិបត្តិការថវិកាបន្ថែមខាងលើនេះ ។

## ជំពូកទី ៥

## ថវិកាថ្នាក់ក្រោមជាតិ

### មាត្រា ១៥.-

ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃមាត្រា ៨៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ និងបទប្បញ្ញត្តិនៃមាត្រា ៣៥ និងមាត្រា ៥៤ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ ចំណូល-ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥ សរុបចំនួន ១ ១០៧ ១៨៦ លានរៀល ត្រូវបានកំណត់ដូចខាងក្រោមនេះ ៖

**ក.ថវិការបស់រដ្ឋបាលរាជធានី ខេត្ត**

- ចំណូលថវិកាសរុប..........................................៧៥៣ ៩៤០ លានរៀល
  - +ចំណូលចរន្តសរុប..........................................៦៦០ ៦៩៩ លានរៀល
    - -ចំណូលសារពើពន្ធ..................................៦៣២ ៣០០ លានរៀល
    - -ចំណូលមិនមែនសារពើពន្ធ..........................២៨ ៣៩៩ លានរៀល
  - +ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ..........................៩៣ ២៤១ លានរៀល
- ចំណាយថវិកាសរុប..........................................៧៥៣ ៩៤០ លានរៀល
  - +ចំណាយចរន្ត..........................................៦២១ ០៧៩ លានរៀល
  - +ចំណាយមូលធន..........................................១៣២ ៨៦១ លានរៀល

**ខ.ថវិការបស់រដ្ឋបាលក្រុង ស្រុក**

- ចំណូលថវិកាសរុប..........................................៨១ ៣០២ លានរៀល
  - +ចំណូលចរន្តសរុប..........................................៣ ៦០១ លានរៀល
    - -ចំណូលមិនមែនសារពើពន្ធ..........................៣ ៦០១ លានរៀល
  - +ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ..........................៧៧ ៧០១ លានរៀល
- ចំណាយថវិកាសរុប..........................................៨១ ៣០២ លានរៀល
  - +ចំណាយចរន្ត..........................................៨១ ៣០២ លានរៀល

**គ.ថវិការបស់រដ្ឋបាលឃុំ សង្កាត់**

- ចំណូលថវិកាសរុប..........................................២៧១ ៩៥៤ លានរៀល
  - +ចំណូលឧបត្ថម្ភពីថវិកាជាតិសរុប..........................២៧១ ៩៥៤ លានរៀល
    - -ចំណូលសង្កាត់ចំណុះរាជធានី................១៨ ០៧៧,៥៣ លានរៀល
    - -ចំណូលសង្កាត់ចំណុះក្រុង....................២១ ៣២១,៩៧ លានរៀល
    - -ចំណូលឃុំ........................................២៣២ ៥៥៤,៥ លានរៀល
- ចំណាយថវិកាសរុប..........................................២៧១ ៩៥៤ លានរៀល
  - +ចំណាយសរុប..........................................២៧១ ៩៥៤ លានរៀល
    - -ចំណាយសង្កាត់ចំណុះរាជធានី................១៨ ០៧៧,៥៣ លានរៀល

-ចំណាយសង្កាត់ចំណុះក្រុង...................២១ ៣២១,៩៧ លានរៀល

-ចំណាយឃុំ.......................................២៣២ ៥៥៤,៥ លានរៀល

ការបែងចែកកញ្ចប់ថវិការួមនេះទៅតាមរាជធានី ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់នីមួយៗក៏ដូចជាការបែងចែកឥណទាននៅផ្ទៃក្នុងថវិកាជាជំពូក គណនី និងអនុគណនី ត្រូវធ្វើឡើងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ១៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៧.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០១៤

នស. ១៤១២.១៤៥៥

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្ថលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ហត្ថលេខា**

**អូន ព័ន្ធមុនីរ័ត្ន**

លេខ:១៤៨៦ស.ណ

**សំណៅដែលមានអង្គេជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ការគ្រប់គ្រងឆ្នាំ២០១៥

## តារាង "ក"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៤ | ឆ្នាំ២០១៥ | ទឹកប្រាក់ | ភាគរយ |
| I. សរុបចំណូលឆ្លងកាត់តេនាគារជាតិ (ក+ខ) | | | | 10.205.627,0 | 11.448.230,0 | 1.242.603,0 | 12,2% |
| ក្នុងនោះចំណូលក្នុងប្រទេស | | | | 9.945.627,0 | 11.146.230,0 | 1.202.603,0 | 12,1% |
| ក. សរុបចំណូលចរន្ត (ក្រ១+ក្រ២) | | | | 9.712.627,0 | 11.014.644,0 | 1.302.017,0 | 13,4% |
| ក្រុមទី១: ចំណូលពិត (ប្រភេទទី១+ប្រភេទទី២) | | | | 9.712.627,0 | 11.014.644,0 | 1.302.017,0 | 13,4% |
| ប្រភេទទី១: ចំណូលសារពើពន្ធ | | | | 8.308.621,2 | 9.548.391,1 | 1.239.769,9 | 14,9% |
| 70 | | | ចំណូលសារពើពន្ធក្នុងស្រុក | 6.544.411,2 | 7.587.691,1 | 1.043.279,9 | 15,9% |
| | 7001 | | ពន្ធផ្ទាល់ (ពន្ធលើផលទុន ប្រាក់ចំណេញ) | 1.776.600,0 | 2.069.000,0 | 292.400,0 | 16,5% |
| | | 70012 | ពន្ធលើប្រាក់ចំណេញ (នីតិបុគ្គល) | 1.357.300,0 | 1.565.000,0 | 207.700,0 | 15,3% |
| | | 70013 | ពន្ធលើប្រាក់បៀវត្ស | 326.500,0 | 385.000,0 | 58.500,0 | 17,9% |
| | | 70014 | ពន្ធលើឈ្នួលចលននិងអចលនទ្រព្យ (រូបវន្តបុគ្គល) | 77.800,0 | 96.000,0 | 18.200,0 | 23,4% |
| | | 70015 | ពន្ធលើឈ្នួលចលននិងអចលនទ្រព្យ (នីតិបុគ្គល) | 15.000,0 | 23.000,0 | 8.000,0 | 53,3% |
| | 7002 | | ពន្ធប្រយោល | 2.933.800,0 | 3.420.000,0 | 486.200,0 | 16,6% |
| | | 70021 | អាករលើផលរបរ | 30.000,0 | 33.000,0 | 3.000,0 | 10,0% |
| | | 70022 | អាករលើតម្លៃបន្ថែម | 1.110.450,0 | 1.310.000,0 | 199.550,0 | 18,0% |
| | | 70025 | អាករលើតម្លៃបន្ថែម របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) | 607.130,0 | 550.000,0 | -57.130,0 | -9,4% |
| | | 70026 | អាករលើតម្លៃបន្ថែម របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 1.046.030,0 | 1.340.000,0 | 293.970,0 | 28,1% |
| | | 70027 | អាករលើតម្លៃបន្ថែម របបនាំចូល ទំនិញជាសម្ភារៈកសិកម្ម (ជាបន្ទុករបស់រដ្ឋ) | 140.190,0 | 187.000,0 | 46.810,0 | 33,4% |
| | 7003 | | អាករពិសេស | 1.713.980,0 | 1.953.400,0 | 239.420,0 | 14,0% |
| | | 70031 | អាករពិសេសលើទំនិញមួយចំនួន | 425.900,0 | 517.000,0 | 91.100,0 | 21,4% |
| | | 70032 | អាករពិសេសលើទំនិញមួយចំនួន របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) | 354.790,0 | 288.200,0 | -66.590,0 | -18,8% |
| | | 70033 | អាករពិសេសលើទំនិញមួយចំនួន របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 863.790,0 | 1.075.200,0 | 211.410,0 | 24,5% |
| | | 70034 | អាករពិសេសលើសេវាមួយចំនួន | 69.500,0 | 73.000,0 | 3.500,0 | 5,0% |
| | 7004 | | អាករលើសេវាដែលបានកំណត់ | 89.690,0 | 95.314,0 | 5.624,0 | 6,3% |
| | | 70041 | អាករលើកាស៊ីណូ | 89.690,0 | 94.114,0 | 4.424,0 | 4,9% |
| | | 70042 | អាករលើឆ្នោត | | 1.200,0 | 1.200,0 | |
| | 7005 | | អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិឬការអនុវត្តន៍សកម្មភាព | 12.991,2 | 26.377,1 | 13.385,9 | 103,0% |
| | | 70052 | ចំណូលពីអាជ្ញាប័ណ្ណក្នុងស្រុក | 12.991,2 | 26.377,1 | 13.385,9 | 103,0% |
| | 7008 | | ចំណូលសារពើពន្ធផ្សេងៗទៀត | 17.350,0 | 23.600,0 | 6.250,0 | 36,0% |
| | | 70081 | ពន្ធតែមប្រ៍ | 5.250,0 | 6.100,0 | 850,0 | 16,2% |
| | | 70082 | ការផាកពិន័យ និងទោសបញ្ញត្តិសារពើពន្ធ | 12.100,0 | 17.500,0 | 5.400,0 | 44,6% |
| 71 | | | ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 1.764.210,0 | 1.960.700,0 | 196.490,0 | 11,1% |
| | 7100 | | ពន្ធនិងអាករលើការនាំចូល | 1.547.270,0 | 1.671.400,0 | 124.130,0 | 8,0% |
| | | 71001 | ពន្ធគយពីការនាំចូល | 873.490,0 | 1.102.000,0 | 228.510,0 | 26,2% |
| | | 71002 | កម្រៃពីការងារគយ | 48.530,0 | 51.000,0 | 2.470,0 | 5,1% |
| | | 71003 | ពន្ធគយលើផលិតផលគេលសិលា | 352.630,0 | 260.000,0 | -92.630,0 | -26,3% |
| | | 71004 | អាករបន្ថែមលើផលិតផលគេលសិលាសម្រាប់ថែទាំផ្លូវថ្នល់ | 249.110,0 | 230.000,0 | -19.110,0 | -7,7% |
| | | 71005 | ផលនៃការលក់ផ្នែកគយ | 540,0 | 800,0 | 260,0 | 48,1% |
| | | 71006 | ពិន័យផ្សេងៗលើការនាំចូល | 21.570,0 | 26.000,0 | 4.430,0 | 20,5% |
| | | 71007 | ការនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ (ជាបន្ទុករបស់រដ្ឋ) | 1.400,0 | 1.600,0 | 200,0 | 14,3% |
| | [illegible] | | ពន្ធនិងអាករលើការនាំចេញ | 216.940,0 | 289.300,0 | 72.360,0 | 33,4% |
| | | 71011 | អាករលើការនាំចេញឈើ | 20.490,0 | 126.000,0 | 105.510,0 | 514,9% |
| | | 71012 | អាករលើការនាំចេញកៅស៊ូ | 51.760,0 | 30.000,0 | -21.760,0 | -42,0% |

# ការគ្រប់គ្រងឆ្នាំ២០១៥

## តារាង "ក"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៤ | ឆ្នាំ២០១៥ | ទឹកប្រាក់ | ភាគរយ |
| | | 71014 | អាករលើការនាំចេញទំនិញផ្សេងៗ | 1.620,0 | 2.800,0 | 1.180,0 | 72,8% |
| | | 71015 | កម្រៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ | 142.640,0 | 130.000,0 | -12.640,0 | -8,9% |
| | | 71016 | ពិន័យផ្សេងៗពីការនាំចេញ | 430,0 | 500,0 | 70,0 | 16,3% |
| **ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ** | | | | 1.404.005,8 | 1.466.252,9 | 62.247,1 | 4,4% |
| 72 | | | ផលខុននៃទ្រព្យសម្បត្តិរដ្ឋ | 148.096,7 | 124.344,9 | -23.751,8 | -16,0% |
| | 7200 | | ផលនៃសម្បទាន និងការជួលដីធ្លី | 137.946,7 | 113.614,9 | -24.331,8 | -17,6% |
| | | 72001 | សម្បទាននេសាទ | 2.750,0 | 3.000,0 | 250,0 | 9,1% |
| | | 72002 | សម្បទានព្រៃឈើ | 39.000,0 | 39.545,0 | 545,0 | 1,4% |
| | | 72003 | សម្បទានពីប្រេងកាត | | 3.116,0 | 3.116,0 | |
| | | 72004 | សម្បទានរ៉ែ | 82.000,0 | 43.747,7 | -38.252,3 | -46,6% |
| | | 72005 | ការជួលដីទំនេរ (មានតែដី) | 14.196,7 | 24.206,2 | 10.009,5 | 70,5% |
| | 7201 | | ផលខុនពីសហគ្រាសសាធារណៈ | 10.150,0 | 10.730,0 | 580,0 | 5,7% |
| | | 72012 | ភាគលាភរបស់សហគ្រាសសាធារណៈ | 10.150,0 | 10.730,0 | 580,0 | 5,7% |
| 73 | | | ផលខុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 1.033.270,5 | 1.255.026,5 | 221.756,0 | 21,5% |
| | 7300 | | ផលខុនសហគ្រាសសាធារណៈរដ្ឋបាល សេវាដំណើរការ(រកចំណេញ) | 481.996,4 | 474.378,9 | -7.617,5 | -1,6% |
| | | 73001 | ផលខុនរបស់អាកាសចរណ៍ស៊ីវិល | 90.000,0 | 92.900,0 | 2.900,0 | 3,2% |
| | | 73003 | ផលខុននៃសកម្មភាពទេសចរណ៍ | 270.952,1 | 256.904,5 | -14.047,6 | -5,2% |
| | | 73004 | ផលខុននៃសកម្មភាពវប្បធម៌ | 13.027,3 | 24.887,9 | 11.860,6 | 91,0% |
| | | 73005 | ផលខុនពីប្រៃសណីយ៍ និងទូរគមនាគមន៍ | 100.000,0 | 93.418,0 | -6.582,0 | -6,6% |
| | | 73006 | ផលខុនពីវិទ្យុ និងទូរទស្សន៍ | 1.799,9 | 1.754,3 | -45,6 | -2,5% |
| | | 73007 | ផលខុននៃសេវាផ្គត់ផ្គង់អគ្គិសនី និងទឹក | 27,0 | 30,0 | 3,0 | 11,1% |
| | | 73008 | ផលខុនផ្សេងៗទៀត | 6.190,1 | 4.484,2 | -1.705,9 | -27,6% |
| | 7301 | | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ | 24.405,0 | 32.323,9 | 7.918,9 | 32,4% |
| | | 73011 | ការលក់សម្ភារៈបរិក្ខារ សម្ភារៈខូចខាត សម្ភារៈសិក្សា | 174,0 | 128,0 | -46,0 | -26,4% |
| | | 73012 | លក់ឯកសារ លតាប័ត្រ និងលិខិតបោះពុម្ពផ្សេងៗ | 20.318,9 | 28.290,6 | 7.971,7 | 39,2% |
| | | 73013 | ផលបានពីការលក់ទ្រព្យសម្បត្តិកំទេចកំទី សត្វពាហនៈ | 163,9 | 9,1 | -154,8 | -94,4% |
| | | 73018 | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ ផ្សេងៗទៀត | 3.748,2 | 3.896,2 | 148,0 | 3,9% |
| | 7302 | | ផលពីការគ្រប់គ្រងរដ្ឋបាល | 452.487,1 | 670.152,9 | 217.665,8 | 48,1% |
| | | 73021 | អាករស្ពានខុត (លិខិតឆ្លងដែននិងទិដ្ឋាការ) | 348.200,0 | 530.347,0 | 182.147,0 | 52,3% |
| | | 73023 | ផលពីការបង្កើតសហគ្រាស | 8.236,4 | 12.339,3 | 4.102,9 | 49,8% |
| | | 73024 | ផលពីការបង់សិទ្ធិប្រឡង | 863,8 | 1.046,0 | 182,2 | 21,1% |
| | | 73025 | ផលពីការលក់ស្លាកលេខ | 24.726,6 | 25.814,2 | 1.087,6 | 4,4% |
| | | 73026 | ចំណូលពីប្រដាប់ភ្លឺ | 3.031,4 | 3.165,1 | 133,7 | 4,4% |
| | | 73027 | ផលពីការត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាននិងសេវាត្រួតពិនិត្យអនាម័យសត្វ | 67.320,0 | 95.496,0 | 28.176,0 | 41,9% |
| | | 73028 | ចំណូលពីការអនុញ្ញាតិរដ្ឋបាល ទំរង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ | 108,9 | 1.945,3 | 1.836,4 | 1686,3% |
| | 7303 | | ការជួលទ្រព្យសម្បត្តិអចល័ត | 16.506,4 | 16.289,5 | -216,9 | -1,3% |
| | | 73031 | ការជួលសហគ្រាសសាធារណៈនៅថ្នាក់រដ្ឋបាលកណ្តាល | 6.408,9 | 5.245,4 | -1.163,5 | -18,2% |
| | | 73032 | ការជួលសហគ្រាសសាធារណៈនៅថ្នាក់ខេត្ត (មន្ទីរជំនាញ) | 9,6 | 9,6 | | |
| | | 73033 | ការជួលសម្ភារៈ និងមធ្យោបាយដឹកជញ្ជូន | 2,9 | 2,9 | | |
| | | 73034 | ការជួលអចលនវត្ថុ (អសង្ហារឹម) | 10.085,0 | 10.471,6 | 386,6 | 3,8% |
| | | 73038 | ផលពីការជួលទ្រព្យសម្បត្តិផ្សេងៗ | | 560,0 | 560,0 | |
| | 7304 | | ការផ្តល់សេវាកម្ម | 57.875,6 | 61.881,3 | 4.005,7 | 6,9% |
| | | 73042 | កម្រៃនៃការថែទាំ | 28.167,7 | 29.449,9 | 1.282,2 | 4,6% |

# ការគ្រប់គ្រងឆ្នាំ២០១៥

## តារាង "ក"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៤ | ឆ្នាំ២០១៥ | ទឹកប្រាក់ | ភាគរយ |
| | | 73043 | សេវាសុរិយោដី | 11.065,4 | 20.000,0 | 8.934,6 | 80,7% |
| | | 73044 | សេវាសំណង់ | 2.734,9 | 7.233,4 | 4.498,5 | 164,5% |
| | | 73045 | សេវាលិខិតថ្កោលទោស | 1.437,6 | 1.602,0 | 164,4 | 11,4% |
| | | 73048 | ផលពីសេវាផ្សេងៗទៀត | 14.470,0 | 3.596,0 | -10.874,0 | -75,1% |
| 74 | | | ចំណូលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | 3.718,6 | 8.864,4 | 5.145,8 | 138,4% |
| | 7401 | | ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | 3.718,6 | 8.864,4 | 5.145,8 | 138,4% |
| 75 | | | ការឧបត្ថម្ភ អំណោយ | | 671,0 | 671,0 | |
| | 7506 | | ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ | | 671,0 | 671,0 | |
| | | 75061 | ពីក្រសួង ស្ថាប័ន | | 671,0 | 671,0 | |
| 76 | | | ផលហិរញ្ញវត្ថុ | 113.000,0 | 77.346,1 | -35.653,9 | -31,6% |
| | 7601 | | ការប្រាក់នៃការឲ្យខ្ចី | 113.000,0 | 77.338,0 | -35.662,0 | -31,6% |
| | | 76011 | ការប្រាក់លើកម្ចី | 113.000,0 | 77.338,0 | -35.662,0 | -31,6% |
| | 7698 | | ផលហិរញ្ញវត្ថុផ្សេងទៀត | | 8,1 | 8,1 | |
| 77 | | | ផលផ្សេងៗ និងផលពិសេស | 105.920,0 | | -105.920,0 | -100,0% |
| | 7702 | | ផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ | 45.920,0 | | -45.920,0 | -100,0% |
| | 7704 | | ចំណូលពីការលក់អាគារ | 60.000,0 | | -60.000,0 | -100,0% |
| ខ.សរុបចំណូលមូលធន (ក្រុមទី១ + ក្រុមទី២) | | | | 493.000,0 | 433.586,0 | -59.414,0 | -12,1% |
| ក្រុមទី១ : ចំណូលពិត (ប្រភេទទី១ + ប្រភេទទី២) | | | | 493.000,0 | 433.586,0 | -59.414,0 | -12,1% |
| ប្រភេទទី១ : ចំណូលពីប្រភពផ្ទាល់ | | | | 233.000,0 | 133.586,0 | -99.414,0 | -42,7% |
| 27 | | | អចលកម្មហិរញ្ញវត្ថុផ្សេងៗ | 233.000,0 | 133.586,0 | -99.414,0 | -42,7% |
| | 2701 | | ការអោយខ្ចី (ការសងត្រឡប់នូវមូលធន) | 233.000,0 | 133.586,0 | -99.414,0 | -42,7% |
| | | 27018 | ការឲ្យខ្ចីផ្សេងៗ | 233.000,0 | 133.586,0 | -99.414,0 | -42,7% |
| ប្រភេទទី២ : ចំណូលពីប្រភពខាងក្រៅ | | | | 260.000,0 | 300.000,0 | 40.000,0 | 15,4% |
| 75 | | | ការឧបត្ថម្ភអំណោយ | | 90.000,0 | 90.000,0 | |
| | 7514 | | ឧបត្ថម្ភកធនមូលធនពីក្រៅប្រទេសទ្វេភាគីសម្រាប់ចំណាយវិនិយោគ | | 49.500,0 | 49.500,0 | |
| | 7515 | | ឧបត្ថម្ភកធនមូលធនពីក្រៅប្រទេសពហុភាគីសម្រាប់ចំណាយវិនិយោគិន | | 40.500,0 | 40.500,0 | |
| 50 | | | ការខ្ចីប្រាក់ និងបំណុលប្រហាក់ប្រហែល | 260.000,0 | 210.000,0 | -50.000,0 | -19,2% |
| | 5002 | | ការខ្ចីក្រៅប្រទេស-ពហុភាគី | 260.000,0 | 210.000,0 | -50.000,0 | -19,2% |
| II. សរុបចំណូលអនុវត្តក្រៅគោលការជាតិ (ក+ខ) | | | | 3.460.000,0 | 3.687.000,0 | 227.000,0 | 6,6% |
| ប្រភេទទី២ : ចំណូលពីប្រភពខាងក្រៅ | | | | 3.460.000,0 | 3.687.000,0 | 227.000,0 | 6,6% |
| 75 | | | ការឧបត្ថម្ភ អំណោយ | 1.210.000,0 | 537.000,0 | -673.000,0 | -55,6% |
| | 7514 | | ឧបត្ថម្ភកធនមូលធនពីក្រៅប្រទេសទ្វេភាគីសម្រាប់ចំណាយវិនិយោគ | 1.210.000,0 | 537.000,0 | -673.000,0 | -55,6% |
| 50 | | | ការខ្ចីប្រាក់ និងបំណុលប្រហាក់ប្រហែល | 2.250.000,0 | 3.150.000,0 | 900.000,0 | 40,0% |
| | 5002 | | ការខ្ចីក្រៅប្រទេស-ពហុភាគី | 2.250.000,0 | 3.150.000,0 | 900.000,0 | 40,0% |

# ការគ្រប់គ្រងឆ្នាំ២០១៥

## តារាង "ខ"

## ចំណាយថវិកាថ្នាក់ជាតិ

ឯកតា: លានរៀល

| ក្រសួង ស្ថាប័ន | សរុបរួម ចំណាយ | ចំណាយចរន្ត | | | | | | ចំណាយមូលធន | | |
|---|---|---|---|---|---|---|---|---|---|---|
| | | សរុប ចំណាយ ចរន្ត | ប្រភេទទី១ មធ្យោបាយ និងសេវា | ប្រភេទទី២ បន្ទុក ហិរញ្ញវត្ថុ | ប្រភេទទី៣ អន្តរាគមន៍ សាធារណៈ | ប្រភេទទី៤ ចំណាយ ផ្សេងៗ | ប្រភេទទី៦ ចំណាយមិន បានគ្រោងទុក | សរុប ចំណាយ មូលធន | ប្រភេទទី១ ការទូទាត់ ប្រាក់កម្ចី | ប្រភេទទី២ អចលកម្ម |
| សរុបរួមចំណាយ | 15.035.229,0 | 9.275.161,0 | 6.965.416,7 | 276.381,0 | 1.574.037,9 | 247.873,4 | 211.452,0 | 5.760.068,0 | 436.568,0 | 5.323.500,0 |
| រដ្ឋបាលកណ្តាល | 8.832.418,7 | 6.759.350,7 | 4.569.935,1 | 276.381,0 | 1.454.779,4 | 246.803,2 | 211.452,0 | 2.073.068,0 | 436.568,0 | 1.636.500,0 |
| មន្ទីរជំនាញរាជធានី ខេត្ត | 2.515.810,3 | 2.515.810,3 | 2.395.481,6 | | 119.258,5 | 1.070,2 | | | | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 3.687.000,0 | | | | | | | 3.687.000,0 | | 3.687.000,0 |
| ក. វិស័យរដ្ឋបាលទូទៅ | 1.681.092,4 | 1.320.011,9 | 789.456,8 | | 285.113,0 | 245.442,1 | | 361.080,5 | | 361.080,5 |
| រដ្ឋបាលកណ្តាល | 1.223.090,3 | 1.223.090,3 | 692.592,4 | | 285.113,0 | 245.384,9 | | | | |
| មន្ទីរជំនាញរាជធានី ខេត្ត | 96.921,6 | 96.921,6 | 96.864,4 | | | 57,2 | | | | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 361.080,5 | | | | | | | 361.080,5 | | 361.080,5 |
| ០១. ព្រះបរមរាជវាំង | 75.613,0 | 75.613,0 | 55.524,0 | | 19.880,0 | 209,0 | | | | |
| ០២. រដ្ឋសភា | 124.474,7 | 124.474,7 | 121.220,7 | | 3.169,0 | 85,0 | | | | |
| ០៣. ព្រឹទ្ធសភា | 56.171,0 | 56.171,0 | 50.191,0 | | 5.900,0 | 80,0 | | | | |
| ០៤. ក្រុមប្រឹក្សាធម្មនុញ្ញ | 7.692,3 | 7.692,3 | 7.627,0 | | 45,0 | 20,3 | | | | |
| ០៥.១. ទីស្តីការគណៈរដ្ឋមន្ត្រី | 438.383,9 | 281.084,0 | 98.886,0 | | 182.048,0 | 150,0 | | 157.299,9 | | 157.299,9 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 157.299,9 | | | | | | | 157.299,9 | | 157.299,9 |
| ០៥.៤. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | 12.352,0 | 12.352,0 | 12.332,0 | | | 20,0 | | | | |
| ០៨. ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | 24.300,8 | 23.360,4 | 23.329,4 | | | 31,0 | | 940,4 | | 940,4 |
| ១. រដ្ឋបាលកណ្តាល | 12.481,4 | 12.481,4 | 12.461,4 | | | 20,0 | | | | |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 10.879,0 | 10.879,0 | 10.868,0 | | | 11,0 | | | | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 940,4 | | | | | | | 940,4 | | 940,4 |
| ០៩. ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | 83.719,3 | 83.719,3 | 81.449,3 | | 1.773,0 | 497,0 | | | | |
| ១០. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | 609.057,4 | 412.637,6 | 143.697,3 | | 24.880,0 | 244.060,3 | | 196.419,9 | | 196.419,8 |
| ១. រដ្ឋបាលកណ្តាល | 392.682,6 | 392.682,6 | 123.776,0 | | 24.880,0 | 244.026,6 | | | | |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 19.955,0 | 19.955,0 | 19.921,3 | | | 33,7 | | | | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 196.419,8 | | | | | | | 196.419,8 | | 196.419,8 |
| ១៤. ក្រសួងផែនការ | 53.083,7 | 47.180,0 | 47.131,4 | | 10,0 | 38,6 | | 5.903,7 | | 5.903,7 |
| ១. រដ្ឋបាលកណ្តាល | 30.933,0 | 30.933,0 | 30.888,0 | | 10,0 | 35,0 | | | | |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 16.247,0 | 16.247,0 | 16.243,4 | | | 3,6 | | | | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 5.903,7 | | | | | | | 5.903,7 | | 5.903,7 |
| ២៨. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | 112.205,4 | 112.205,4 | 71.405,9 | | 40.768,0 | 31,5 | | | | |
| ១. រដ្ឋបាលកណ្តាល | 71.613,6 | 71.613,6 | 30.820,6 | | 40.768,0 | 25,0 | | | | |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 40.591,8 | 40.591,8 | 40.585,3 | | | 6,5 | | | | |
| ៣០. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | 13.299,0 | 13.299,0 | 13.207,0 | | 2,0 | 90,0 | | | | |
| ៣១. អាជ្ញាធរសវនកម្មជាតិ | 9.671,3 | 9.671,3 | 9.651,3 | | 9,0 | 11,0 | | | | |
| ៣៣. ស្ថាប័នប្រឆាំងអំពើពុករលួយ | 27.561,4 | 27.561,4 | 27.463,4 | | | 98,0 | | | | |
| ៣៤. ក្រសួងមុខងារសាធារណៈ | 33.507,2 | 32.990,5 | 26.341,1 | | 6.629,0 | 20,4 | | 516,7 | | 516,7 |
| ១. រដ្ឋបាលកណ្តាល | 23.741,7 | 23.741,7 | 17.094,7 | | 6.629,0 | 18,0 | | | | |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 9.248,8 | 9.248,8 | 9.246,4 | | | 2,4 | | | | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 516,7 | | | | | | | 516,7 | | 516,7 |
| ខ. វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ | 2.441.060,5 | 2.316.182,9 | 2.281.948,1 | | 34.203,8 | 31,0 | | 124.877,6 | | 124.877,6 |
| រដ្ឋបាលកណ្តាល | 2.345.052,9 | 2.287.052,9 | 2.252.823,1 | | 34.203,8 | 26,0 | | 58.000,0 | | 58.000,0 |
| មន្ទីរជំនាញរាជធានី ខេត្ត | 29.130,0 | 29.130,0 | 29.125,0 | | | 5,0 | | | | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 66.877,6 | | | | | | | 66.877,6 | | 66.877,6 |
| ០៦. ក្រសួងការពារជាតិ | 1.322.800,0 | 1.322.800,0 | 1.305.562,0 | | 17.238,0 | | | | | |
| ០៧.១. ក្រសួងមហាផ្ទៃ-សន្តិសុខសាធារណៈ | 878.995,0 | 820.995,0 | 808.700,0 | | 12.295,0 | | | 58.000,0 | | 58.000,0 |
| ០៧.២. ក្រសួងមហាផ្ទៃ-រដ្ឋបាលទូទៅ | 172.634,5 | 105.756,9 | 102.876,9 | | 2.880,0 | | | 66.877,6 | | 66.877,6 |
| ១. រដ្ឋបាលកណ្តាល | 105.756,9 | 105.756,9 | 102.876,9 | | 2.860,0 | | | | | |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | | | | | | | | | | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 65.877,5 | | | | | | | 66.877,6 | | 66.877,6 |

ព្រះបរមរាជវាំង

# ការគ្រប់គ្រងឆ្នាំ២០១៥
## តារាង "ខ"
## ចំណាយថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ក្រសួង ស្ថាប័ន | សរុបរួម ចំណាយ | ចំណាយចរន្ត | | | | | | ចំណាយមូលធន | | |
|---|---|---|---|---|---|---|---|---|---|---|
| | | សរុប ចំណាយ ចរន្ត | ប្រភេទទី១ មធ្យោបាយ និងសេវា | ប្រភេទទី២ បន្ទុក ហិរញ្ញវត្ថុ | ប្រភេទទី៣ អន្តរាគមន៍ សាធារណៈ | ប្រភេទទី៤ ចំណាយ ផ្សេងៗ | ប្រភេទទី៦ ចំណាយមិន បានគ្រោងទុក | សរុប ចំណាយ មូលធន | ប្រភេទទី១ ការខ្ចីទាក់ ប្រាក់កម្ចី | ប្រភេទទី២ អចលកម្ម |
| ២៦. ក្រសួងយុត្តិធម៌ | 66.631,0 | 66.631,0 | 64.809,2 | | 1.790,8 | 31,0 | | | | |
| ១. យុត្តិធម៌ | 28.434,5 | 28.434,5 | 26.638,7 | | 1.775,8 | 20,0 | | | | |
| ២. តុលាការកំពូល | 3.577,0 | 3.577,0 | 3.556,0 | | 15,0 | 6,0 | | | | |
| ៣. សាលាឧទ្ធរណ៍ | 4.004,5 | 4.004,5 | 4.004,5 | | | | | | | |
| ៤. ក្រុមប្រឹក្សានៃអង្គចៅក្រម | 1.485,0 | 1.485,0 | 1.485,0 | | | | | | | |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 29.130,0 | 29.130,0 | 29.125,0 | | | 5,0 | | | | |
| គ. វិស័យសង្គមកិច្ច | 4.182.645,6 | 3.584.504,8 | 2.942.883,5 | | 640.401,4 | 1.219,9 | | 598.140,8 | | 598.140,8 |
| រដ្ឋបាលកណ្តាល | 1.424.957,1 | 1.389.957,1 | 860.314,6 | | 529.109,5 | 533,0 | | 35.000,0 | | 35.000,0 |
| មន្ទីរជំនាញរាជធានី ខេត្ត | 2.194.547,7 | 2.194.547,7 | 2.082.568,9 | | 111.291,9 | 686,9 | | | | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 563.140,8 | | | | | | | 563.140,8 | | 563.140,8 |
| ១១. ក្រសួងព័ត៌មាន | 55.466,3 | 52.854,0 | 52.780,5 | | 40,0 | 33,5 | | 2.612,3 | | 2.612,3 |
| ១. រដ្ឋបាលកណ្តាល | 37.858,4 | 37.858,4 | 37.795,4 | | 40,0 | 23,0 | | | | |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 14.995,6 | 14.995,6 | 14.985,1 | | | 10,5 | | | | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 2.612,3 | | | | | | | 2.612,3 | | 2.612,3 |
| ១២. ក្រសួងសុខាភិបាល | 1.296.906,5 | 1.023.141,0 | 545.248,0 | | 477.310,4 | 582,6 | | 273.765,5 | | 273.765,5 |
| ១. រដ្ឋបាលកណ្តាល | 719.425,0 | 719.425,0 | 279.096,0 | | 440.103,4 | 225,6 | | | | |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 303.716,0 | 303.716,0 | 266.152,0 | | 37.207,0 | 357,0 | | | | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 273.765,5 | | | | | | | 273.765,5 | | 273.765,5 |
| ១៦. ក្រសួងអប់រំ យុវជន និងកីឡា | 1.813.590,4 | 1.583.308,4 | 1.505.550,3 | | 77.441,7 | 316,4 | | 230.282,0 | | 230.282,0 |
| ១. អប់រំ | 340.369,7 | 305.369,7 | 300.904,3 | | 4.345,4 | 120,0 | | 35.000,0 | | 35.000,0 |
| ២. ឧត្តមសិក្សា | 53.082,2 | 53.082,2 | 50.981,8 | | 2.100,4 | | | | | |
| ៣. យុវជននិងកីឡា | 43.581,3 | 43.581,3 | 29.523,3 | | 14.058,0 | | | | | |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 1.181.275,2 | 1.181.275,2 | 1.124.140,9 | | 56.937,9 | 196,4 | | | | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 195.282,0 | | | | | | | 195.282,0 | | 195.282,0 |
| ១៨. ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | 55.406,8 | 55.406,8 | 53.289,5 | | 2.095,0 | 22,3 | | | | |
| ១. រដ្ឋបាលកណ្តាល | 37.812,1 | 37.812,1 | 35.699,8 | | 2.095,0 | 17,3 | | | | |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 17.594,7 | 17.594,7 | 17.589,7 | | | 5,0 | | | | |
| ១៩. ក្រសួងបរិស្ថាន | 60.420,1 | 37.389,8 | 36.763,8 | | 583,0 | 43,0 | | 23.030,3 | | 23.030,3 |
| ១. រដ្ឋបាលកណ្តាល | 23.175,9 | 23.175,9 | 22.568,9 | | 580,0 | 27,0 | | | | |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 14.213,9 | 14.213,9 | 14.194,9 | | 3,0 | 16,0 | | | | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 23.030,3 | | | | | | | 23.030,3 | | 23.030,3 |
| ២១. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 666.183,4 | 645.058,9 | 598.249,0 | | 46.755,0 | 54,9 | | 21.124,5 | | 21.124,5 |
| ១. រដ្ឋបាលកណ្តាល | 51.522,8 | 51.522,8 | 16.307,8 | | 35.195,0 | 20,0 | | | | |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 593.536,1 | 593.536,1 | 581.941,2 | | 11.560,0 | 34,9 | | | | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 21.124,5 | | | | | | | 21.124,5 | | 21.124,5 |
| ២៣. ក្រសួងធម្មការនិងសាសនា | 39.391,6 | 34.585,1 | 34.570,9 | | | 14,2 | | 4.806,5 | | 4.806,5 |
| ១. រដ្ឋបាលកណ្តាល | 16.134,4 | 16.134,4 | 16.124,4 | | | 10,0 | | | | |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 18.450,7 | 18.450,7 | 18.446,5 | | | 4,2 | | | | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 4.806,5 | | | | | | | 4.806,5 | | 4.806,5 |
| ២៤. ក្រសួងកិច្ចការនារី | 35.289,5 | 35.289,5 | 29.011,9 | | 6.203,5 | 74,1 | | | | |
| ១. រដ្ឋបាលកណ្តាល | 16.923,6 | 16.923,6 | 13.690,0 | | 3.183,5 | 50,1 | | | | |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 18.365,9 | 18.365,9 | 15.321,9 | | 3.020,0 | 24,0 | | | | |
| ៣២. ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | 159.991,0 | 117.471,3 | 87.419,6 | | 29.972,6 | 78,9 | | 42.519,7 | | 42.519,7 |
| ១. រដ្ឋបាលកណ្តាល | 85.071,7 | 85.071,7 | 57.622,9 | | 27.408,8 | 40,0 | | | | |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 32.399,6 | 32.399,6 | 29.796,7 | | 2.564,0 | 38,9 | | | | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 42.519,7 | | | | | | | 42.519,7 | | 42.519,7 |
| ឃ. វិស័យសេដ្ឋកិច្ច | 4.295.133,5 | 994.232,4 | 951.128,3 | | 41.923,7 | 1.180,4 | | 3.300.901,1 | | 3.300.901,1 |
| រដ្ឋបាលកណ្តាល | 1.404.021,4 | 799.021,4 | 764.205,0 | | 33.957,1 | 859,3 | | 605.000,0 | | 605.000,0 |
| មន្ទីរជំនាញរាជធានី ខេត្ត | 195.211,0 | 195.211,0 | 186.923,3 | | 7.966,6 | 321,1 | | | | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 2.695.901,1 | | | | | | | 2.695.901,1 | | 2.695.901,1 |

# ការគ្រប់គ្រងឆ្នាំ២០១៥
## តារាង "ខ"
## ចំណាយថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ក្រសួង ស្ថាប័ន | សរុបរួម ចំណាយ | ចំណាយចរន្ត | | | | | | ចំណាយមូលធន | | |
|---|---|---|---|---|---|---|---|---|---|---|
| | | សរុប ចំណាយ ចរន្ត | ប្រភេទទី១ មធ្យោបាយ និងសេវា | ប្រភេទទី២ បន្ទុក ហិរញ្ញវត្ថុ | ប្រភេទទី៣ អន្តរាគមន៍ សាធារណៈ | ប្រភេទទី៤ ចំណាយ ផ្សេងៗ | ប្រភេទទី៦ ចំណាយមិន បានគ្រោងទុក | សរុប ចំណាយ មូលធន | ប្រភេទទី១ ការទូទាត់ ប្រាក់កម្ចី | ប្រភេទទី២ អចលកម្ម |
| ០៩.៣. ផ្នែកលេខាធិការដ្ឋានអាកាសចរស៊ីវិល | 69.565,1 | 47.878,9 | 37.307,9 | | 10.561,0 | 10,0 | | 21.686,2 | | 21.686,2 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 21.686,2 | | | | | | | 21.686,2 | | 21.686,2 |
| ១៣. ក្រសួងរ៉ែនិងថាមពល | 443.130,2 | 25.657,8 | 25.023,6 | | 569,9 | 64,3 | | 417.472,4 | | 417.472,4 |
| ១. រដ្ឋបាលកណ្ដាល | 15.609,4 | 15.609,4 | 15.294,2 | | 269,9 | 45,3 | | | | |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 10.048,4 | 10.048,4 | 9.729,4 | | 300,0 | 19,0 | | | | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 417.472,4 | | | | | | | 417.472,4 | | 417.472,4 |
| ១៥. ក្រសួងពាណិជ្ជកម្ម | 141.295,3 | 114.155,8 | 109.900,6 | | 4.219,2 | 36,0 | | 27.139,5 | | 27.139,5 |
| ១. រដ្ឋបាលកណ្ដាល | 100.750,1 | 100.750,1 | 96.513,9 | | 4.219,2 | 17,0 | | | | |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 13.405,7 | 13.405,7 | 13.386,7 | | | 19,0 | | | | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 27.139,5 | | | | | | | 27.139,5 | | 27.139,5 |
| ១៧. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 326.356,5 | 150.296,5 | 131.981,4 | | 18.014,6 | 300,5 | | 176.060,0 | | 176.060,0 |
| ១. រដ្ឋបាលកណ្ដាល | 126.263,1 | 106.263,1 | 95.441,1 | | 10.572,0 | 250,0 | | 20.000,0 | | 20.000,0 |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 44.033,4 | 44.033,4 | 36.540,3 | | 7.442,6 | 50,5 | | | | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 156.060,0 | | | | | | | 156.060,0 | | 156.060,0 |
| ២០. ក្រសួងអភិវឌ្ឍន៍ជនបទ | 412.584,3 | 128.242,2 | 128.059,9 | | | 182,3 | | 284.342,1 | | 284.342,1 |
| ១. រដ្ឋបាលកណ្ដាល | 213.766,2 | 93.766,2 | 93.616,2 | | | 150,0 | | 120.000,0 | | 120.000,0 |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 34.476,0 | 34.476,0 | 34.443,7 | | | 32,3 | | | | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 164.342,1 | | | | | | | 164.342,1 | | 164.342,1 |
| ២២. ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | 85.540,6 | 46.212,0 | 44.387,2 | | 1.775,0 | 49,8 | | 39.328,6 | | 39.328,6 |
| ១. រដ្ឋបាលកណ្ដាល | 35.203,0 | 35.203,0 | 33.399,0 | | 1.775,0 | 29,0 | | | | |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 11.009,0 | 11.009,0 | 10.988,2 | | | 20,8 | | | | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 39.328,6 | | | | | | | 39.328,6 | | 39.328,6 |
| ២៤. ក្រសួងសាធារណការនិងដឹកជញ្ជូន | 1.773.647,2 | 323.585,8 | 323.322,5 | | | 263,3 | | 1.450.061,4 | | 1.450.061,4 |
| ១. រដ្ឋបាលកណ្ដាល | 630.311,8 | 285.311,8 | 285.161,8 | | | 150,0 | | 345.000,0 | | 345.000,0 |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 38.274,0 | 38.274,0 | 38.160,7 | | | 113,3 | | | | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 1.105.061,4 | | | | | | | 1.105.061,4 | | 1.105.061,4 |
| ២៧. ក្រសួងទេសចរណ៍ | 65.534,7 | 54.161,7 | 53.577,2 | | 560,0 | 24,5 | | 11.373,0 | | 11.373,0 |
| ១. រដ្ឋបាលកណ្ដាល | 41.964,3 | 41.964,3 | 41.397,3 | | 560,0 | 7,0 | | | | |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 12.197,4 | 12.197,4 | 12.179,9 | | | 17,5 | | | | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 11.373,0 | | | | | | | 11.373,0 | | 11.373,0 |
| ២៩. ក្រសួងធនធានទឹកនិងឧតុនិយម | 848.279,2 | 74.511,4 | 68.243,7 | | 6.044,0 | 223,7 | | 773.767,8 | | 773.767,8 |
| ១. រដ្ឋបាលកណ្ដាល | 173.953,9 | 53.953,9 | 47.953,9 | | 5.820,0 | 180,0 | | 120.000,0 | | 120.000,0 |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 20.557,5 | 20.557,5 | 20.289,8 | | 224,0 | 43,7 | | | | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 653.767,8 | | | | | | | 653.767,8 | | 653.767,8 |
| ៣៩. ក្រសួងឧស្សាហកម្មនិងសិប្បកម្ម | 129.200,5 | 29.530,3 | 29.324,3 | | 180,0 | 26,0 | | 99.670,2 | | 99.670,2 |
| ១. រដ្ឋបាលកណ្ដាល | 18.320,7 | 18.320,7 | 18.119,7 | | 180,0 | 21,0 | | | | |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 11.209,6 | 11.209,6 | 11.204,6 | | | 5,0 | | | | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 99.670,2 | | | | | | | 99.670,2 | | 99.670,2 |
| ៩៩. ចំណាយមិនទាន់បែងចែកមានមុខសញ្ញា | 2.435.297,0 | 1.060.229,0 | | 276.381,0 | 572.396,0 | | 211.452,0 | 1.375.068,0 | 436.568,0 | 938.500,0 |
| - ចំណាយចរន្តក្នុងការអនុវត្តគម្រោង | 129.500,0 | 129.500,0 | | | 129.500,0 | | | | | |
| - បន្ទុកហិរញ្ញវត្ថុ | 276.381,0 | 276.381,0 | | 276.381,0 | | | | | | |
| - ឧបត្ថម្ភរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ | 442.896,0 | 442.896,0 | | | 442.896,0 | | | | | |
| - ចំណាយមិនបានគ្រោងទុក | 211.452,0 | 211.452,0 | | | | | 211.452,0 | | | |
| - ការទូទាត់ប្រាក់កម្ចី | 436.568,0 | | | | | | | 436.568,0 | 436.568,0 | |
| - [illegible] | 321.700,0 | | | | | | | 321.700,0 | | 321.700,0 |
| - [illegible] | 316.800,0 | | | | | | | 316.800,0 | | 316.800,0 |
| - [illegible] | 300.000,0 | | | | | | | 300.000,0 | | 300.000,0 |

ព្រះបរមរាជវាំង / ROYAUME DU CAMBODGE / LE MINISTRE DU PALAIS ROYAL

## ការគ្រប់គ្រងឆ្នាំ២០១៥

## តារាង "ខ១"

## ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស

ឯកតា:លានរៀល

| ឈ្មោះគម្រោង | តម្លៃគម្រោង | កម្រិតទុនវិនិយោគចែកតាមឆ្នាំ | | | |
|---|---|---|---|---|---|
| | | ២០១៥ | ២០១៦ | ២០១៧ | សរុប៣ឆ្នាំ |
| **សរុបរួម** | 51.347.166 | 4.913.860 | 4.964.565 | 5.469.486 | 15.347.912 |
| គម្រោងមានហិរញ្ញប្បទាន (គម្រោងវិនិយោគជាទុន) | 19.072.057 | 3.161.203 | 3.002.333 | 1.915.508 | 8.079.043 |
| គម្រោងមិនទាន់មានហិរញ្ញប្បទាន (គម្រោងវិនិយោគជាទុន) | 32.275.109 | 1.752.658 | 1.962.233 | 3.553.978 | 7.268.868 |
| **ទីស្តីការគណៈរដ្ឋមន្ត្រី** | 1.192.056 | 179.906 | 159.197 | 136.479 | 475.582 |
| គម្រោងមានហិរញ្ញប្បទាន (គម្រោងវិនិយោគជាទុន) | 1.055.720 | 147.612 | 130.616 | 110.316 | 388.544 |
| គម្រោងសាងសង់អគារមជ្ឈមណ្ឌលព័ត៌មាន និងបច្ចេកវិទ្យា | 60.750 | 34.830 | 17.415 | | 52.245 |
| គម្រោងបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម | 978.467 | 109.470 | 109.889 | 110.316 | 329.675 |
| គម្រោងជួសជុលប្រាសាទមេបុណ្យ | 16.504 | 3.312 | 3.312 | | 6.623 |
| គម្រោងមិនទាន់មានហិរញ្ញប្បទាន (គម្រោងវិនិយោគជាទុន) | 136.336 | 32.294 | 28.581 | 26.163 | 87.038 |
| គម្រោងសាងសង់អគារស្នាក់ការកណ្តាលរបស់អគ្គលេខាធិការដ្ឋានគណៈវិស្វករកម្ពុជា | 8.093 | 3.464 | 1.732 | 1.732 | 6.928 |
| គម្រោងកសាងសមត្ថភាព និងជំនួយបច្ចេកទេសដល់អង្គភាពទិន្នន័យនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរមីន | 5.732 | 584 | 630 | 680 | 1.894 |
- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីសហលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៨០ អនក្រ.តត ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលចំនួនគណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **ស៊ូ សារី** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៦ ជាអភិបាលរង នៃគណៈអភិបាលខេត្តព្រះវិហារ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤៧៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ និងទៅក្នុងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/៤២១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានផ្ទេរបញ្ចូលមន្ត្រីរាជការចំនួន ០២រូប ទៅក្នុងឋានន្តរស័ក្តិនាយក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែពិសេស នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន ក្រសួងអប់រំ យុវជន និងកីឡា :

**ក- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

១- លោក **អ៊ុក ចាន់ថន** ពីភ្នាក់ងាររដ្ឋបាល ថ្នាក់លេខ ៨ មកនាយក្រមការ ថ្នាក់លេខ ៦

**ខ- ក្រសួងអប់រំ យុវជន និងកីឡា**

២- លោកស្រី **ម៉ែន ស៊ីណា** ពីគ្រូបង្រៀនកម្រិតបឋម ថ្នាក់លេខ ៤ មកគ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែពិសេស ថ្នាក់លេខ ៦។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤៧០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១.-** តម្លើងឋានន្តរស័ក្តិជាករណីពិសេស ជូនមន្ត្រីរាជការ ចំនួន ៤១ រូប ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស មកឋានន្តរស័ក្តិវរមន្ត្រីការបរទេសនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដូចមានរាយនាមខាងក្រោម ៖

| | |
|---|---|
| ១- លោក **សេង សេងឈាន** | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៣<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៦ |
| ២- លោកស្រី **រត្ន ម៉ានី** | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៤<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៦ |
| ៣- លោក **អ៊ុង គឹមដង់** | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៥<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៧ |
| ៤- លោក **នួន ស៊ីនឿន** | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៥<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៧ |
| ៥- លោក **ឥន្ទ តារា** | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៥<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៧ |
| ៦- លោក **រដ្ឋ ផល្លី** | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៥<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៧ |
| ៧- លោក **ថោ ម៊ុនថា** | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៥<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៧ |
| ៨- លោក **ណុំ ពិសិដ្ឋ** | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៦<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៧ |
| ៩- លោក **ឆាយ សុខហេង** | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៦<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៧ |
| ១០- លោក **ជ័យ រដ្ឋា** | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៦<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៧ |
| ១១- លោកស្រី **គឹមសួគ៌ សុវណ្ណារី** | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៦<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៧ |
| ១២- លោក **ហុក សុតា** | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៦<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៧ |
| ១៣- លោក **ខិល ដារ៉ា** | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៧<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៨ |
| ១៤- លោក **កៅ សំណាង** | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៧<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៨ |
| ១៥- លោក **រ័ត្ន ចាន់ខាសនា** | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៧<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៨ |
| ១៦- លោកស្រី **ថោង សុគន្ធារី** | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៧<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៨ |

| | |
|---|---|
| ១៧- លោក ស៊ិន ស៊ីយ៉ា | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៧<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៨ |
| ១៨- លោក ម៉ែន វណ្ណា | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៧<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៨ |
| ១៩- លោក គីម សុវណ្ណា | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៧<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៨ |
| ២០- លោក ហូ ពេជ្រមោលី | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៧<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៨ |
| ២១- លោក ទុយ តាពិរៈ | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៧<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៨ |
| ២២- លោក ស៊ុន សុធារ៉ាត | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៧<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៨ |
| ២៣- លោក យៀប សំណាង | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៨<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៩ |
| ២៤- លោក ឆូច សុធីរ៉ា | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៨<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៩ |
| ២៥- លោក ឆាម សុធី | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៨<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៩ |
| ២៦- លោកស្រី ផែន សាវនី | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៨<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៩ |
| ២៧- លោក សេក ច័ន្ទសង្វារ | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៨<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៩ |
| ២៨- លោក ចឺយ វិចិត្ត | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៨<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៩ |
| ២៩- លោក ប៊ុខ សីហា | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៨<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៩ |
| ៣០- លោក សេង សុជាតិ | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៨<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៩ |
| ៣១- លោកស្រី កែវ សុផាន់ណារ៉ា | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៨<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៩ |
| ៣២- លោក ខៀវ រិទ្ធីយ៉ា | ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៨<br>មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៩ |

៣៣- លោក **ឃុន សុវណ្ណារិទ្ធ** ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៨
មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៩

៣៤- លោក **គាម សារ៉ាត់** ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៨
មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៩

៣៥- លោកស្រី **ទូច សុផារត្ន** ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៨
មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៩

៣៦- លោក **គាត សុវណ្ណានី** ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៨
មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៩

៣៧- លោក **ហេង ពៅ** ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៨
មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៩

៣៨- លោក **ផៃ គឹមឈុន** ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៨
មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៩

៣៩- លោក **ខៃ លន** ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៨
មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៩

៤០- លោក **ឡុង សុខន** ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៨
មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៩

៤១- លោក **លី សុខអេង** ពីឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ថ្នាក់លេខ ៨
មកឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៩

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៤៩១ . អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងថ្នាក់ជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១.-** តម្លើងថ្នាក់ប្រចាំឆ្នាំជូនមន្ត្រីរាជការចំនួន ៩៥ នាក់ ក្នុងឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម របស់ក្រសួងអប់រំ យុវជន និងកីឡា ចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៤ តទៅ ដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១-លោក | **លី សទ្ធិ** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ២-លោក | **ឱម សិទ្ធី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៣-លោក | **សេខ ម៉ុនធឿន** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៤-លោក | **ច័ន្ទ រ័ត្ន** | ពីវរមន្ត្រី ថ្នាក់លេខ ៧ | មកវរមន្ត្រី ថ្នាក់លេខ ៦ |
| ៥-លោក | **ស៊ូ សុផាន** | ពីវរមន្ត្រី ថ្នាក់លេខ ៨ | មកវរមន្ត្រី ថ្នាក់លេខ ៧ |
| ៦-ឯកឧត្តម | **សាន មន្តិយ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ ១០ | មកវរមន្ត្រី ថ្នាក់លេខ ៩ |
| ៧-លោកស្រី | **ធីម សុខុម** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៦ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៥ |
| ៨-លោក | **ជា ជាតិ** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៦ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៥ |
| ៩-លោកស្រី | **ទន់ សុគន្ធនារី** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៦ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៥ |
| ១០-លោក | **ខៀវ ឈុនលី** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៦ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៥ |
| ១១-លោក | **អ៊ី ស៊ាងលី** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៦ |
| ១២-លោកស្រី | **អន កិត្យាស៊ី** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៦ |
| ១៣-លោក | **ម៉ុល សុរិទ្ធ** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៦ |
| ១៤-លោក | **ហ៊ុន សាមុត** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៦ |
| ១៥-លោក | **ដួង មាសចំរើន** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៦ |
| ១៦-លោក | **ធម្ម អន្តារ៉ា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៦ |
| ១៧-លោក | **ឌីម ស៊ាន** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៦ |
| ១៨-លោក | **កែ ហាន** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៦ |
| ១៩-លោកស្រី | **ព្រាប សុត្ថុង** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៦ |

| | | | |
|---|---|---|---|
| ២០-លោក | ពាន់ ឆាយ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៦ |
| ២១-លោក | ហ៊ុន ម៉េងស្រ៊ី | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៦ |
| ២២-លោក | គីម សុវណ្ណគិរី | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៦ |
| ២៣-លោក | ឃាង មុព្រឹក្ស | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៦ |
| ២៤-លោក | ស៊ីម សេដ្ឋា | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៦ |
| ២៥-លោក | ទី សែត | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៦ |
| ២៦-លោក | ទី សុខន | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ២៧-លោកស្រី | ហេង សាគីម | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ២៨-លោក | អ៊ឹង ម៉ោហុក | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ២៩-លោក | ចាន់ ខេង | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ៣០-លោក | សេក សុខា | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ៣១-លោក | ឈុន ហុក | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ៣២-លោក | ទេព ឧត្តី | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ៣៣-លោកស្រី | ប៊ី គឹមសែន | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ៣៤-លោកស្រី | លី សុធឿន | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ៣៥-លោក | ស៊ីម ឆួន | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ៣៦-លោក | សេង គឹមហេង | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ៣៧-លោកស្រី | ស្ទួស ម៉ីន | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |

| | | | |
|---|---|---|---|
| ៣៨-លោក | តុល នរិទ្ធ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ៣៩-លោក | លឹម សុថាច | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ៤០-លោក | ឈុន សុផល | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ៤១-លោក | សួង យ៉េន | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ៤២-លោក | តាត ហាប់ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧ |
| ៤៣-លោកស្រី | មាស វណ្ណា | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ៤៤-លោក | ប៉ាល់ ដែស | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ៤៥-លោក | ឡោ ឆវណ្ណា | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ៤៦-លោក | ពុត សាមិត្ត | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ៤៧-លោកស្រី | គេង សុភាលក្ស្មី | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ៤៨-លោកស្រី | អ៊ុង សាង | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ៤៩-ឯកឧត្តម | សំ ថ៉ា | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ៥០-លោក | ហាក់ ធឿន | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ៥១-លោក | មាស សិត | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ៥២-ឯកឧត្តម | សៀង សុវណ្ណា | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ៥៣-លោក | ចាន់ សុតា | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ៥៤-លោក | ប៉ៅ សំអាង | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ៥៥-ឯកឧត្តម | នៅ រ៉ា | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |

| | | | |
|---|---|---|---|
| ៥៦-លោក | ឌី បុណ្ណា | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ៥៧-លោក | អ៊ុក ឧត្តរៈ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ៥៨-លោក | រស់ ចណ្ណាជ័យ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ៥៩-លោក | តួច សុខចាន់ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ៦០-លោក | សួស យុត្តារី | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ៦១-លោក | ឈួន ផាណា | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ៦២-លោកស្រី | សុខ យ៉ាន | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ៦៣-លោក | អឹម សុនថន | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ៦៤-លោក | ញាន សាខឿន | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ៦៥-លោក | សុខ សំអឿន | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ៦៦-លោកស្រី | មាស តិរុណា | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨ |
| ៦៧-លោក | សោម សាឡឿន | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ៦៨-ឯកឧត្តម | ហោ ប៉េង | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ៦៩-លោក | យឹម សំណាង | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ៧០-លោក | ជា សឿន | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ៧១-ឯកឧត្តម | ទូច វិសាលសុខ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ៧២-លោក | លឹម សុធា | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ៧៣-លោក | ហាប់ ច័ន្ទណារ៉ា | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |

| | | | |
|---|---|---|---|
| ៧៤-លោក | ម៉ា វុទ្ធី | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ៧៥-លោក | ជា វុធ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ៧៦-លោកស្រី | ម៉ុន ជានស៊ីផល | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ៧៧-លោកស្រី | ញ៉េប ពិដោរ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ៧៨-លោក | យស់ ផល្លី | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ៧៩-លោកស្រី | ម៉ែន សំអុនសុន្ទរី | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ៨០-លោក | ហេង ផេង | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ៨១-លោក | គួច គូលំអ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ៨២-លោក | នួន វីរ៉ា | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ៨៣-លោក | ជុនសៀង ចាវរិទ្ធ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ៨៤-លោក | នុត សុថន | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ៨៥-លោកស្រី | ឆាន់ស៊ុន ឆាវី | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ៨៦-លោក | ខៀវ សំអុល | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ៨៧-លោក | សុខ ស៊ីដេត | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ៨៨-លោក | សិត ខន | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ៨៩-លោក | ពិន វណ្ណារ៉ូ | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ៩០-លោក | គួង តាព | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ៩១-លោក | ទិត រ៉ាវី | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |

| | | | |
|---|---|---|---|
| ៩២-លោក | **ឃាន សំបូរ** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ៩៣-លោក | **សុភ វ៉ាឌី** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ៩៤-លោកជំទាវ | **សៀន ឯមធនធីម** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |
| ៩៥-លោក | **ម៉ិន នុំ** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ |

**មាត្រា ២ .-** តម្លើងថ្នាក់តាមសញ្ញាបត្រជូនមន្ត្រីរាជការចំនួន ០៣ នាក់ ក្នុងឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម របស់ក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១-លោកស្រី | **ឆាយគីម សុទ្ធាវី** | ពីវរមន្ត្រី ថ្នាក់លេខ ៨ | មកវរមន្ត្រី ថ្នាក់លេខ ៧ |
| ២-លោក | **អ៊ុក សិទ្ធិជាតិ** | ពីវរមន្ត្រី ថ្នាក់លេខ ៨ | មកវរមន្ត្រី ថ្នាក់លេខ ៧ |
| ៣-លោក | **អេង គីមលី** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៥ | មកគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ |

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ- កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**..១៤៩៤...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរសក្តិ ជាកិច្ចបច្ឆាមរណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ដំឡើងឋានន្តរសក្តិថ្នាក់ វរសេនីយ៍ឯក ជាកិច្ចបច្ឆាមរណៈ ជូនសព

១-វរសេនីយ៍ទោ **ជួខ ញ៉េន** អត្តលេខ ០០៥០៦៥ នាយសេនាធិការរង កងពលតូចអន្តរាគមន៍លេខ៨ កងពលធំអន្តរាគមន៍លេខ៣ អគ្គបញ្ជាការដ្ឋាន

២-វរសេនីយ៍ទោ **ឃឹម ឡឿន** អត្តលេខ ០១២១២២ នាយសេនាធិការរង កងពលតូចអន្តរាគមន៍លេខ៨ កងពលធំអន្តរាគមន៍លេខ៣ អគ្គបញ្ជាការដ្ឋាន

៣-វរសេនីយ៍ទោ **ជួន ធិន** អត្តលេខ ០០៤៥៤៩ នាយសេនាធិការរង កងពលតូចអន្តរាគមន៍លេខ៨ កងពលធំអន្តរាគមន៍លេខ៣ អគ្គបញ្ជាការដ្ឋាន

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ:..១៦៤..ស.សរ

## សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលនិងបំពេញបន្ថែមសមាជិកក្រុមការងារ ថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធី នយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់ កាលទី៣របស់រាជរដ្ឋាភិបាល កម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្ម តាមមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានផ្លាស់ប្តូរសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្រការ អនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តមួយចំនួន ដូចខាងក្រោម៖

១. លោក **រដ្ឋ សារ៉ាវុធ** អគ្គនាយករងនៃអគ្គនាយកដ្ឋានឧស្សាហកម្ម ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ពីសមាជិកក្រុមការងារខេត្តកោះកុង មកជាសមាជិកក្រុមការងារខេត្តកំពត

២. លោកស្រី **គង់ សិទ្ធិកា** អគ្គនាយករង នៃអគ្គនាយកដ្ឋានសហគ្រាស ធុនតូច និងមធ្យម និងសិប្បកម្ម ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ពីសមាជិកក្រុមការងារខេត្តកែប មកជាសមាជិកក្រុមការងារខេត្តកំពត ។

**ប្រការ២ .-**

ត្រូវបានបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តកណ្តាល ដូចខាងក្រោម៖

១.ឯកឧត្តមបណ្ឌិត **គុណ ញឹម** អគ្គនាយក នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ជាសមាជិកក្រុមការងារខេត្តកណ្តាល ។

**ប្រការ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋបាល ខេត្តពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ និងប្រការ២ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០១៤

ជ.នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

**ស ខេង**

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រដ្ឋបាលថ្នាក់ក្រោមជាតិ
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៦៦ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០១ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៦០៨ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- យោងតាមសំណើរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន/.

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្តនៅតាមរាជធានី ខេត្ត ដូចខាងក្រោម៖

| | |
|---|---|
| ១- រាជធានីភ្នំពេញ | ២- ខេត្តកណ្តាល |
| ៣- ខេត្តកំពង់ចាម | ៤- ខេត្តបាត់ដំបង |
| ៥- ខេត្តព្រៃវែង | ៦- ខេត្តសៀមរាប |
| ៧- ខេត្តតាកែវ | ៨- ខេត្តត្បូងឃ្មុំ |
| ៩- ខេត្តបន្ទាយមានជ័យ | ១០- ខេត្តកំពង់ស្ពឺ |
| ១១- ខេត្តកំពង់ធំ | ១២- ខេត្តកំពត |
| ១៣- ខេត្តកំពង់ឆ្នាំង | ១៤- ខេត្តស្វាយរៀង |
| ១៥- ខេត្តពោធិ៍សាត់ | ១៦- ខេត្តក្រចេះ |
| ១៧- ខេត្តព្រះសីហនុ | ១៨- ខេត្តកោះកុង |
| ១៩- ខេត្តព្រះវិហារ | ២០- ខេត្តរតនគិរី |
| ២១- ខេត្តស្ទឹងត្រែង | ២២- ខេត្តឧត្តរមានជ័យ |
| ២៣- ខេត្តមណ្ឌលគិរី | ២៤- ខេត្តប៉ៃលិន |
| ២៥- ខេត្តកែប | |

**ប្រការ២ .-**

គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀននៅតាមរាជធានី ខេត្ត នីមួយៗមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | ប្រធាន |
| - អភិបាលរងរាជធានី ខេត្ត១រូប | អនុប្រធាន |
| - ស្នងការនគរបាលរាជធានី ខេត្ត | សមាជិក |
| - មេបញ្ជាការកងរាជអាវុធហត្ថរាជធានី ខេត្ត | សមាជិក |
| - មេបញ្ជាការឬតំណាងយោធភូមិភាគ(ចំពោះខេត្តដែលមានយោធភូមិភាគឈរជើង) | សមាជិក |
| - មេបញ្ជាការឬតំណាងកងនាវិកខេមរភូមិន្ទមូលដ្ឋានដែនសមុទ្រ(ចំពោះខេត្តដែលមានកងនាវិកខេមរភូមិន្ទឈរជើង) | សមាជិក |
| - មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត | សមាជិក |
| - មេបញ្ជាការកងពលតូច ង៧០(ចំពោះរាជធានីភ្នំពេញ) | សមាជិក |
| - ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត | សមាជិក |
| - ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត | សមាជិក |
| - ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត | សមាជិក |
| - ប្រធានមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត | សមាជិក |

- ប្រធានមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍រាជធានី ខេត្ត សមាជិក
- ប្រធានមន្ទីរកិច្ចការនារីរាជធានី ខេត្ត សមាជិក
- ប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត សមាជិក
- ប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត សមាជិក
- ប្រធានមន្ទីរធម្មការនិងសាសនារាជធានី ខេត្ត សមាជិក
- ប្រធានមន្ទីរឧស្សាហកម្មនិងសិប្បកម្មរាជធានី ខេត្ត សមាជិក
- ប្រធានមន្ទីរព័ត៌មានរាជធានី ខេត្ត សមាជិក
- ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត សមាជិក
- ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត សមាជិក
- ប្រធានសាខាគយនិងរដ្ឋាករាជធានី ខេត្ត សមាជិក
- ប្រធានសាខាកាំកុងត្រូលរាជធានី ខេត្ត សមាជិក

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀននៅតាមរាជធានី ខេត្ត នីមួយៗ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**ប្រការ៣ .-**

គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត មានភារកិច្ចដូចតទៅ៖

**ក- ចំពោះខេត្ត ដែលមានព្រំប្រទល់ជាប់ប្រទេសថៃ ឡាវ វៀតណាម៖**

- សហប្រតិបត្តិការនិងសម្របសម្រួលវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀនរវាងខេត្ត នៃប្រទេសជិតខាងដែលមានព្រំប្រទល់ជាប់គ្នា
- ធ្វើឱ្យកាន់តែប្រសើរឡើងនូវការផ្លាស់ប្តូរព័ត៌មានតាមព្រំដែន រាល់បញ្ហាដែលពាក់ព័ន្ធនឹងការដាំដុះ ការផលិត ការចរាចរ ការជួញដូរ ការប្រើប៊ំពានគ្រឿងញៀន និងការចរាចរសារធាតុគីមីផ្សំ
- បង្កើតនីតិវិធីរួមមួយ សម្រាប់ទំនាក់ទំនងខាងបណ្តាញផ្លាស់ប្តូរប្រមូលព័ត៌មានពីគ្នាទៅវិញទៅមករវាងខេត្តនៃប្រទេសជិតខាងដែលមានព្រំប្រទល់ជាប់គ្នាដូចមានចែងក្នុងអនុស្សរណៈនៃការយោគយល់គ្នា
- បង្កើតឱ្យមានទំនាក់ទំនងជិតស្និទ្ធជាមួយមន្ត្រីក្នុងវិស័យផ្សេងៗ សម្រាប់ការងារត្រួតពិនិត្យគ្រឿងញៀនដោយឈរលើស្មារតីគិតគូដល់ផលប្រយោជន៍រួម
- រៀបចំឱ្យមានកម្មវិធីជួបប្រជុំជាប្រចាំជាមួយភាគីនៃខេត្តជាប់ព្រំដែននៃប្រទេសជិតខាងឱ្យបានទៀងទាត់ដើម្បីពិភាក្សានិងកសាងផែនការសកម្មភាពរួមគ្នា និងពង្រីកកិច្ចសហប្រតិបត្តិការនេះ
- គ្រប់គ្រងនិងដឹកនាំការិយាល័យទំនាក់ទំនងព្រំដែនលើបញ្ហាគ្រឿងញៀន(BLO)។

ក្រៅពីភារកិច្ចខាងលើ ខេត្តដែលជាប់ព្រំដែនក៏ត្រូវបំពេញភារកិច្ចដូចរាជធានី ខេត្ត នៅក្នុងផ្ទៃប្រទេសដែលមានចែងអំពីភារកិច្ច ក្នុងចំណុច"ខ"ខាងក្រោមនេះដែរ។

**ខ- ចំពោះរាជធានី ខេត្ត នៅក្នុងផ្ទៃប្រទេស៖**

- កសាងផែនការសកម្មភាពប្រយុទ្ធប្រឆាំងគ្រឿងញៀនថ្នាក់រាជធានី ខេត្តរបស់ខ្លួន ដោយយកចិត្តទុកដាក់សំខាន់៖

• ការងារពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់អំពី ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន វិជានការស៊ើបអង្កេត ស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសពាក់ព័ន្ធនឹងការផលិត ការដាំដុះ ការចរាចរ ការជួញដូរ ការប្រើបំពានគ្រឿងញៀន សារជាតុគីមីផ្សំ និងនីតិវិធីកសាងសំណុំរឿងបញ្ជូនទៅតុលាការ
• ការងារអប់រំបង្ការ ការពារការប្រើបំពានគ្រឿងញៀន តាមរយៈយុទ្ធនាការឃោសនា ផ្សព្វផ្សាយ ធ្វើឱ្យមានការយល់ដឹងជាទូទៅអំពីគ្រោះថ្នាក់ ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន
• រៀបចំឱ្យមានកម្មវិធីនិងកន្លែងសម្រាប់ព្យាបាលអ្នកញៀនគ្រឿងញៀន នៅក្នុងរាជធានី ខេត្ត របស់ខ្លួន

- រៀបចំឱ្យមានប្រព័ន្ធផ្លាស់ប្តូរព័ត៌មានពីរាជធានី ខេត្តមួយទៅខេត្តមួយ រាល់បញ្ហាដែលពាក់ព័ន្ធនឹងការផលិត ការដាំដុះ ការចរាចរ ការជួញដូរ និងការប្រើបំពានគ្រឿងញៀននិងសារជាតុគីមីផ្សំ
- ប្រមូលផ្តុំការដឹកនាំដល់មន្ត្រីដែលស្ថិតក្នុងវិស័យផ្សេងៗដែលពាក់ព័ន្ធដល់ការត្រួតពិនិត្យគ្រឿងញៀន សំដៅធ្វើឱ្យមានប្រសិទ្ធភាពខ្ពស់
- ចូលរួមប្រជុំតាមការអញ្ជើញរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាសនិងប្រចាំឆ្នាំ និងរាយការណ៍ភ្លាមៗជាបន្ទាន់ក្នុងករណីពិសេស មកអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនប្រគល់ជូន។

**ប្រការ៤ .-**

ទីតាំងរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត អាស្រ័យដោយប្រធានគណៈកម្មាធិការជាអ្នកសម្រេច។ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្តមានសិទ្ធិប្រើត្រារបស់រាជធានី ខេត្ត ដើម្បីដំណើរការការងាររបស់ខ្លួន។

**ប្រការ៥ .-**

គណៈកម្មាធិការនេះ មានលេខាធិការដ្ឋានមួយជាសេនាធិការ ក្នុងការដឹកនាំ គ្រប់គ្រង លើកផែនការតាមដាន វាយតម្លៃ ការអនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន។

អនុប្រធានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត គឺជាប្រធានលេខាធិការដ្ឋាននេះ។

**ប្រការ៦ .-**

ប្រធានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ត្រូវរៀបចំបង្កើតឱ្យមានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន នៅថ្នាក់ខណ្ឌ ក្រុង ស្រុក និងឃុំ សង្កាត់ ដើម្បីបំពេញភារកិច្ចប្រយុទ្ធប្រឆាំងគ្រឿងញៀននៅថ្នាក់មូលដ្ឋាន។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដែលជាអាណាប័កផ្ទេរសិទ្ធិ ត្រូវម្ចាស់ការក្នុងការរៀបចំបង្កើតឱ្យមានកញ្ចប់ថវិកាដោយឡែក សម្រាប់ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនប្រចាំឆ្នាំនៅក្នុងរាជធានី ខេត្តរបស់ខ្លួន។

**ប្រការ៧ .-**

សេចក្តីសម្រេចលេខ០៩ សសរ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤ ស្តីពីគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត ក្រុង និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។/៚

**ប្រការ៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងយុត្តិធម៌

លេខ:...២១៤.....ប្រក.ដនស

# ប្រកាសអន្តរក្រសួង

## ស្ដីពី

## នីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងកេរ្តិ៍អាករពារ និងការរឹបអូស ចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌

- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដីនិងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងនិងការប្រើប្រាស់អគារសហកម្មសិទ្ធិ
- បានឃើញប្រកាសអន្តរក្រសួងលេខ ៥៩ ប្រក.ដនស/១១ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញប្រកាសអន្តរក្រសួងលេខ ៣០ កយ.ដនស.ប្រក/១៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី
- តាមការចាំបាច់ក្នុងការអនុវត្តក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### ប្រការ ១._ គោលបំណង

ប្រកាសនេះ មានគោលបំណងធានានូវប្រសិទ្ធភាពនៃការចុះបញ្ជី ទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ឱ្យបានត្រឹមត្រូវទៅតាមក្រមនីតិវិធីរដ្ឋប្បវេណី និងបទដ្ឋានគតិយុត្តផ្សេងទៀត ។

### ប្រការ ២._ គោលដៅ

ប្រកាសនេះ មានគោលដៅបញ្ញត្តអំពីនីតិវិធីនៃការចុះបញ្ជីតាមរយៈលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីរបស់តុលាការដែលបានផ្ញើមកស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី ចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ។

### ប្រការ ៣._ វិសាលភាព

ប្រកាសនេះ មានវិសាលភាពអនុវត្តលើការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ដូចខាងក្រោម ៖

ក. ដីដែលមិនទាន់បានចុះបញ្ជី។

ខ. ចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលមិនទាន់បានចុះបញ្ជី។

### ប្រការ ៤._ និយមន័យ

វាក្យស័ព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងប្រកាសនេះ មានន័យដូចតទៅ ៖

១. អចលនវត្ថុដែលមិនទាន់បានចុះបញ្ជី គឺសំដៅលើដី និងចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលមិនទាន់បានចុះបញ្ជី ។

២. ដីដែលមិនទាន់បានចុះបញ្ជី គឺសំដៅលើដីដែលមិនទាន់បានចុះក្នុងសៀវភៅចុះបញ្ជី ហើយដែលតុលាការបានសន្មតថាកូនបំណុលនៃការអនុវត្ត ឬកូនបំណុលជាកម្មសិទ្ធិករ ឬភោគីនៃដីនោះ ដោយផ្អែកតាមមាត្រា ៤១៧ កថាខណ្ឌទី ៣ និងមាត្រា ៥៤១ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៣. ចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលមិនទាន់បានចុះបញ្ជី គឺសំដៅលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលមិនទាន់បានចុះក្នុងសៀវភៅគោលបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ដែលតុលាការបានសន្មតថាកូនបំណុលនៃការអនុវត្ត ឬកូនបំណុលជាកម្មសិទ្ធិករ ឬជាម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍នៃចំណែកឯកជននៃអគារសហកម្មសិទ្ធិនោះ ដោយផ្អែកតាមមាត្រា ៤១៧ កថាខណ្ឌទី៣ និងមាត្រា៥៤១ កថាខណ្ឌ ទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៤. នីតិវិធីចុះបញ្ជីដីលើកដំបូង គឺសំដៅលើនីតិវិធីចុះបញ្ជីដីដែលមិនទាន់បានចុះបញ្ជីទៅក្នុងសៀវភៅចុះបញ្ជី ។

៥. នីតិវិធីចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិលើកដំបូង គឺសំដៅលើនីតិវិធីចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលមិនទាន់បានចុះបញ្ជីទៅក្នុងសៀវភៅចុះបញ្ជី។

៦. លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី គឺសំដៅលើលិខិតរបស់តុលាការដែលបានផ្ញើមករដ្ឋបាលសុរិយោដី ដើម្បីស្នើសុំធ្វើនីតិវិធីចុះបញ្ជី។

## ជំពូកទី ២
## យន្តការ និងនីតិវិធីនៃការចុះបញ្ជី

### ប្រការ ៥._ ស្ថាប័នមានសមត្ថកិច្ច

១. ស្ថាប័នមានសមត្ថកិច្ចទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី គឺរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ឬរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលអចលនវត្ថុតាំងនៅ ។

នៅពេលរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ឬរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ បានទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី ត្រូវចុះលេខនៃការទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីក្នុងសៀវភៅទទួលពាក្យសុំចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ដែលបានបង្កើតឡើងដាច់ដោយឡែកពីសៀវភៅទទួលពាក្យសុំផ្សេងទៀត តាមប្រការ ៥ នៃប្រកាសអន្តរក្រសួងលេខ ៣០ កយ.ដនស.ប្រក/១៣ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ។

ប្រសិនបើរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ បានទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌនោះ ត្រូវផ្ញើច្បាប់ដើមនៃលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីនោះ និងឯកសារពាក់ព័ន្ធផ្សេងទៀត ទៅកាន់រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ដែលអចលនវត្ថុតាំងនៅដោយគ្មានការយឺតយ៉ាវ ។

នៅពេលរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត បានទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្តនោះ ត្រូវផ្ញើច្បាប់ដើមនៃលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីនោះ និងឯកសារពាក់ព័ន្ធផ្សេងទៀត រួមទាំងលិខិតអនុញ្ញាតឱ្យចាប់ផ្តើមនីតិវិធីចុះបញ្ជីលើកដំបូង ទៅកាន់រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលអចលនវត្ថុតាំងនៅដើម្បីអនុវត្តនីតិវិធីចុះបញ្ជីដោយគ្មានការយឺតយ៉ាវ ។

២. ស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី គឺរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ។

៣. ចំពោះលំដាប់នៃការចុះបញ្ជី ត្រូវអនុលោមតាមប្រការ ៧ នៃប្រកាសអន្តរក្រសួងលេខ ៣០ កយ.ដនស.ប្រក/១៣ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ។

**ប្រភេទ ៦._ លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី**

នៅពេលចេញដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំ ឬដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬដីកាចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ក្រឡាបញ្ជីត្រូវធ្វើលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីទៅស្ថាប័នមានសមត្ថកិច្ចឱ្យចាប់ផ្តើមនីតិវិធីចុះបញ្ជីដីលើកដំបូង និង/ឬចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិលើកដំបូង និងចុះបញ្ជីអំពីការរឹបអូស ឬរឹបអូសជាបណ្តោះអាសន្ន ឬចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងតាមទម្រង់និងខ្លឹមសារដូចខាងក្រោម ៖

ក. កម្មវត្ថុ: ១. ចាប់ផ្តើមនីតិវិធីចុះបញ្ជីដីលើកដំបូងនិង/ឬចំណែកឯកជននៃអគារសហកម្មសិទ្ធិលើកដំបូង ។

២. សរសេរអំពីខ្លឹមសារនៃការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ឬការរឹបអូស ។

ខ. អត្តសញ្ញាណនៃអចលនវត្ថុ: ទីតាំងដី ទំហំដី លេខក្បាលដីនៃទីតាំងអគារសហកម្មសិទ្ធិ ឈ្មោះអគារសហកម្មសិទ្ធិ និងលេខប័ណ្ណ ។

គ. កម្មសិទ្ធិករ ឬភោគីនៃដីដែលត្រូវបានសន្មត : ឈ្មោះ និងអាសយដ្ឋាន ។ ចំពោះអគារសហកម្មសិទ្ធិ ត្រូវសរសេរឈ្មោះ និងអាសយដ្ឋានរបស់បុគ្គលដែលត្រូវបានសន្មតជាកម្មសិទ្ធិករ ឬអ្នកជួលអចិន្ត្រៃយ៍ ។

ឃ. គោលបំណងនៃការចុះបញ្ជី : ការរឹបអូសជាបណ្តោះអាសន្ន ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ឬការរឹបអូសកម្មសិទ្ធិ សិទ្ធិភោគៈ ឬសិទ្ធិជួលអចិន្ត្រៃយ៍ (ចំពោះតែចំណែកឯកជននៃអគារសហកម្មសិទ្ធិ) ។

ង. មូលហេតុ : ដីកាសម្រេចឱ្យរឹបអូសជាបណ្តោះអាសន្ន ដីកាសម្រេចអំពីការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ឬដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំលេខ....ចុះថ្ងៃទី ខែ ឆ្នាំ ។

ច. - ចំពោះការរក្សាការពារ សរសេរឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់បំណុល

- ចំពោះការរឹបអូស សរសេរឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត

ឆ. - ចំពោះការរក្សាការពារ សរសេរឈ្មោះ និងអាសយដ្ឋានរបស់កូនបំណុល

- ចំពោះការរឹបអូស សរសេរឈ្មោះ និងអាសយដ្ឋានរបស់កូនបំណុលនៃការអនុវត្ត

ឯកសារភ្ជាប់ មានដូចខាងក្រោម ៖

- ចំពោះការរក្សាការពារ :
    - ឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន
    - ឯកសារចម្លងយថាភូតនៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែង
    - ឯកសារនៃសេចក្តីបញ្ជាក់ដំបូងអំពីកម្មសិទ្ធិ ជាអាទិ៍ របស់កូនបំណុលនៃការចាត់ចែងរក្សាការពារចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ដែលមានចែងនៅក្នុងមាត្រា៥៤១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។
- ចំពោះការរឹបអូស :
    - ឯកសារចម្លងយថាភូតនៃដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំ
    - ឯកសារបញ្ជាក់អំពីកម្មសិទ្ធិ ជាអាទិ៍ របស់កូនបំណុលនៃការរឹបអូសអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ដូចមានចែងក្នុងមាត្រា ៤១៧ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**ប្រការ ៧._ ការចាប់ផ្តើមនីតិវិធីចុះបញ្ជីលើកដំបូង**

១. នៅពេលដែលបានទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី ដោយផ្អែកលើដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ឬដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំចំពោះដីដែលមិនទាន់បានចុះបញ្ជី និងទទួលបានលិខិតអនុញ្ញាតឱ្យចាប់ផ្តើមធ្វើនីតិវិធីនៃការចុះបញ្ជីដីលើកដំបូង រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវចាប់ផ្តើមនីតិវិធីចុះបញ្ជីដោយគ្មានការយឺតយ៉ាវ ដោយអនុវត្តតាមបទដ្ឋានគតិយុត្តទាក់ទងនឹងនីតិវិធីនៃការចុះបញ្ជីដីលើកដំបូងដែលនៅជាធរមាន ។

២. នៅពេលដែលបានទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី ដោយផ្អែកលើដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ឬដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំចំពោះចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលមិនទាន់បានចុះបញ្ជី និងទទួលបានលិខិតអនុញ្ញាតឱ្យចាប់ផ្តើមធ្វើនីតិវិធីនៃការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិលើកដំបូង រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវចាប់ផ្តើមនីតិវិធីចុះបញ្ជីដោយគ្មានការយឺតយ៉ាវ ដោយអនុវត្តតាមបទដ្ឋានគតិយុត្តទាក់ទងនឹងនីតិវិធីនៃការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិលើកដំបូងដែលនៅជាធរមាន ។

៣. នៅពេលធ្វើការចុះបញ្ជីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ ខាងលើនេះ បញ្ញត្តិនៃប្រការ ៨០ និងប្រការ ៨១ នៃប្រកាសអន្តរក្រសួងលេខ ៣០ កយ.ជនស.ប្រក/១៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

**ប្រការ ៨._ ការចុះបញ្ជីអំពីការចាត់ចែងរក្សាការពារនិងការរឹបអូសតាមលិខិតផ្ទុកផ្តាក់**

១. នៅពេលដែលការចុះបញ្ជីដី ឬចំណែកឯកជននៃអគារសហកម្មសិទ្ធិដោយអនុវត្តតាមនីតិវិធីដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ ត្រូវបានបញ្ចប់ រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ដែលអចលនវត្ថុតាំងនៅត្រូវសរសេរនៅក្នុងខ្ទង់ត្រង់ "បន្ទុកលើអចលនវត្ថុ" អំពីការចុះបញ្ជីនោះ យោងតាមលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី និងតាមប្រកាសអន្តរក្រសួងលេខ ៥៩ ប្រក.ជ.ន.ស/១១ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណីដោយគ្មានការយឺតយ៉ាវ ។

២. នៅពេលធ្វើការចុះបញ្ជីដែលបានកំណត់ក្នុងកថាខណ្ឌទី១ នៃប្រការនេះ បញ្ញត្តិនៃប្រការ៨៣ នៃប្រកាសអន្តរក្រសួងលេខ ៣០ កយ.ជនស.ប្រក/១៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

**ប្រការ ៩._ ភារកិច្ចរបស់ម្ចាស់បំណុលនៃការអនុវត្តជាអាទិ៍**

ម្ចាស់បំណុល ឬម្ចាស់បំណុលនៃការអនុវត្តដែលមានក្នុងលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី មានភារកិច្ចបង់ជាមុននូវការចំណាយក្នុងការចុះបញ្ជីដីលើកដំបូង និងការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិលើកដំបូង ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ ផ្អែកតាមមាត្រា ៣៧៤ និងមាត្រា ៥៣៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**ប្រការ ១០._ ការលើកចោលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី**

រដ្ឋបាលសុរិយោដីដែលបានចាប់ផ្តើមនីតិវិធីដូចមានចែងក្នុងប្រការ៧ នៃប្រកាសនេះ អាចលើកចោលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីបាន ចំពោះករណីដូចខាងក្រោមនេះ ៖

១. ក្នុងករណីដែលរកឃើញច្បាស់ថា កូនបំណុល ឬកូនបំណុលនៃការអនុវត្តមិនមែនជាកម្មសិទ្ធិករ ឬភោគីនៃដីដែលជាកម្មវត្ថុនៃការចុះបញ្ជីនៅពេលកំពុងដំណើរការនីតិវិធីចុះបញ្ជីលើកដំបូង ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ ដោយផ្អែកតាមបទដ្ឋានគតិយុត្តទាក់ទងនឹងការចុះបញ្ជីដីលើកដំបូងដែលនៅជាធរមាន ។

២. ក្នុងករណីដែលរកឃើញច្បាស់ថា កូនបំណុល ឬកូនបំណុលនៃការអនុវត្តមិនមែនជាកម្មសិទ្ធិករ ឬអ្នកជួលអចិន្ត្រៃយ៍នៃចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលជាកម្មវត្ថុនៃការចុះបញ្ជី នៅពេលកំពុងដំណើរការនីតិវិធីដូចមានចែងក្នុងប្រការ៧ នៃប្រកាសនេះ ដោយផ្អែកតាមបទដ្ឋានគតិយុត្តទាក់ទងនឹងការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលនៅជាធរមាន ។

៣. ក្នុងករណីដែលតុលាការអនុវត្តពុំបានផ្តល់ឯកសារភ្ជាប់ ដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ មកជាមួយនឹងលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី ។

៤. ក្នុងករណីដែលពុំបានផ្តល់ឯកសារចាំបាច់សម្រាប់នីតិវិធីចុះបញ្ជី ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ ក្នុងអំឡុងពេលសមរម្យដែលកំណត់ដោយមន្ត្រីចុះបញ្ជី ។

៥. ក្នុងករណីដែលតុលាការអនុវត្តពុំបានផ្តល់ទៅឱ្យរដ្ឋបាលសុរិយោដីនូវសោហ៊ុយសេវាផ្សេងៗទាក់ទងនឹងការចុះបញ្ជីដីលើកដំបូង ឬការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិលើកដំបូង ដែលម្ចាស់បំណុល ឬម្ចាស់បំណុលនៃការអនុវត្តបានបង់តាមប្រការ ៩ នៃប្រកាសនេះរួចហើយ ។

៦. ក្នុងករណីដែលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីត្រូវបានដាក់ខុសសមត្ថកិច្ច ។

៧. ករណីចំណុចដែលមាននៅក្នុងលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីផ្ទុយនឹងប្រកាសនេះ ។

ក្នុងករណីមានការលើកចោលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីដោយផ្អែកតាមប្រការនេះ រដ្ឋបាលសុរិយោដីត្រូវធ្វើលិខិតលើកចោលជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់អំពីមូលហេតុនៃការលើកចោល ហើយត្រូវផ្ញើលិខិតលើកចោលនេះ និងលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី រួមទាំងឯកសារភ្ជាប់ទៅតុលាការដែលបានចេញលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីនោះ ។

### ប្រការ ១១._ នីតិវិធីនៃការចុះបញ្ជីលើកដំបូង ក្រោយពីការលើកចោល

១. ទោះបីជាមានការលើកចោលនូវលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី ដោយផ្អែកតាមប្រការ ១០ កថាខណ្ឌទី ១ ចំណុចទី ១ និងចំណុចទី២ ក៏ដោយ ក៏ការលើកចោលនេះពុំរាំងដល់ការអនុវត្តនីតិវិធីចុះបញ្ជីលើកដំបូងចំពោះដី ឬចំណែកឯកជននៃអគារសហកម្មសិទ្ធិតាមការស្នើសុំពីបុគ្គលដែលត្រូវជាកម្មសិទ្ធិករឬភោគីនៃដីពិតប្រាកដ ឬកម្មសិទ្ធិករឬអ្នកជួលអចិន្ត្រៃយ៍ចំណែកឯកជននៃអគារសហកម្មសិទ្ធិពិតប្រាកដឡើយ។

២. ម្ចាស់សិទ្ធិពិតប្រាកដដែលមានចែងនៅក្នុងកថាខណ្ឌទី១ ខាងលើ ជាអ្នកទទួលបន្ទុកលើសោហ៊ុយសម្រាប់ការចុះបញ្ជីលើកដំបូងចំពោះដី ឬចំណែកឯកជននៃអគារសហកម្មសិទ្ធិនោះ។

ក្នុងករណីដែលម្ចាស់សិទ្ធិពិតប្រាកដនោះ មិនបានបង់សោហ៊ុយនោះទេ មន្ត្រីចុះបញ្ជីមានសិទ្ធិផ្អាកនីតិវិធីចុះបញ្ជីលើកដំបូងចំពោះដី ឬចំណែកឯកជននៃអគារសហកម្មសិទ្ធិនោះបាន ។

## ជំពូកទី៣

## អន្តរប្បញ្ញត្តិ

### ប្រការ ១២._ អន្តរប្បញ្ញត្តិ

ប្រកាសនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីចុះបញ្ជីតាមរយៈលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការចាត់ចែងរក្សាការពារ និងការរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីដែលត្រូវបានផ្ញើមករដ្ឋបាលសុរិយោដីមានសមត្ថកិច្ចមុនការអនុវត្តប្រកាសអន្តរក្រសួងនេះ។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលនីតិវិធីចុះបញ្ជីទាំងនោះត្រូវបានអនុវត្តរួចហើយ ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ ១៣._ កាលបរិច្ឆេទនៃការអនុវត្ត**

ប្រកាសនេះ ត្រូវអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ១៤._ និរាករណ៍នៃបទប្បញ្ញត្តិដែលផ្ទុយ**

បទប្បញ្ញត្តិទាំងឡាយណាដែលមានអានុភាពពេលប្រកាសនេះត្រូវបានអនុវត្ត ហើយផ្ទុយនឹងបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវចាត់ទុកថាគ្មានអានុភាពត្រឹមទំហំដែលផ្ទុយនឹងប្រកាសនេះ ចាប់ពីថ្ងៃដែលប្រកាសនេះត្រូវបានអនុវត្ត ។

រាជធានីភ្នំពេញ ថ្ងៃទី..២១..ខែ..វិច្ឆិកា..ឆ្នាំ២០១៤

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**អ៊ឹម ឈុនលឹម**

**រដ្ឋមន្ត្រី**
**ក្រសួងយុត្តិធម៌**

**អង្គ.វង្សវឌ្ឍនា**

**ចម្លងជូន:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
  "ដើម្បីជូនជ្រាប"
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តុលាការគ្រប់ជាន់ថ្នាក់
- មហាអយ្យការអមតុលាការកំពូល
- មហាអយ្យការអមសាលាឧទ្ធរណ៍
- អយ្យការអមសាលាដំបូងរាជធានី ខេត្ត
- សាលារាជធានី ខេត្ត
- មន្ទីរ ជនសស "ដើម្បីមុខការ"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : [illegible] ១០

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និង បំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ ០២០២/១៤ ស.ត.ស.ព ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ខេមបូឌាន ធីម វើក អ៊ិនដាសស្ទ្រី ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៤។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន ខេមបូឌាន ធីម វើក អ៊ិនដាសស្ទ្រី (CAMBODIAN TEAM WORK INDUSTRY Co., Ltd.) តំណាងដោយ លោក WU YADONG សញ្ជាតិចិន អាយុ៤៧ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G35149057 ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ មានរាសយដ្ឋានបច្ចុប្បន្ន៖ BLD 10, ABP, No.70 Phoenix Rd, Nanjing, Jiangsu, China. ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
| --- | --- |
| ស្បែកជើង | ១៥២០ |

**ផ្លាកឈ្មោះរោងចក្រ៖** *"រោងចក្រស្បែកជើង ខេមបូឌាន ធីម វើក អ៊ិនដាសស្ទ្រី"*
**ទីតាំងរោងចក្រ៖** *"តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (ភូមិពូធឿង ឃុំបិតត្រាំង និងភូមិស្នាច់ដែង ឃុំរាម ស្រុកព្រៃនប់) ខេត្តព្រះសីហនុ"*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងដំឡើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទបញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងបរិក្ខារនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទបញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌនៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងរាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនត្រូវបានជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ នឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព០៣ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្របានផ្តល់ជូនក្រសួងបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ របាយការណ៍ផលិតកម្ម ប្រចាំខែ ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បានបង់កម្រៃសេវាកម្មវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំបន្តសុពលភាពទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ផលិតកម្មប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទម្រង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែនីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេល នៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណី ខកខានក្នុងការផ្តល់ទិន្នន័យ និងរបាយការណ៍តាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សម្គាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទបញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាម មាត្រា៣៩ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗ ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រះសីហនុ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តព្រះសីហនុ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ០២៤០ ឧសសិ.ឧក.ប្រកស.១០

## ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និង បំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ ២៥៨៨/១៤ គ.វ.ក ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ស្តារ ៨ អេស៊ា ភីធីអ៊ី អិលធីឌី ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៤។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន ស្តារ ៨ អេស៊ា ភីធីអ៊ី អិលធីឌី (STAR 8 ASIA PTY LTD.) តំណាងដោយលោក MAIMON YACOV សញ្ជាតិអូស្ត្រាលី អាយុ៤៥ឆ្នាំ កាន់លិខិតឆ្លងដែនលេខ E4052845 ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១១ មានអាសយដ្ឋានបច្ចុប្បន្ន៖ U 21 15 Beach, St Port, Melbourne 3207, Australia. ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| បន្ទះសូឡា | ២៣១០ |

**ផ្លាកឈ្មោះរោងចក្រ៖** *"រោងចក្រផលិតបន្ទះស្ពឺឡា ស្តារ ៨ អេស៊ា ភីធីអ៊ី អិលធីឌី"*
**ទីតាំងរោងចក្រ៖** *"ដីឡូត៍លេខ ៨៦០ ភូមិទួលពង្រ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ"*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងជំទើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទបញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទបញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌនៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងរាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនត្រូវបានជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃយ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ នឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព០៣ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្របានផ្តល់ជូនក្រសួងបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ របាយការណ៍ផលិតកម្ម ប្រចាំខែ ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បានបង់កម្រៃសេវាកម្មវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំបន្តសុពលភាពទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ផលិតកម្មប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទម្រង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែនីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេល នៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណី ខកខានក្នុងការផ្តល់ទិន្នន័យ និងរបាយការណ៍តាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចែចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សម្គាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទបញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ រាចដកហូតស្របតាម មាត្រា៣៩ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗ ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែ[illegible] ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ :០[illegible].១០

## ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែ សម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ ០៣០៩/១៤ ស.គ.ស.ព ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន អ៊ីសាសស៊ុន អយហ្វៀល អេឃ្វីបម៉ិន មេនូហ្វេកជើរីង (ខេមបូឌា) ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន អ៊ីសាសស៊ុន អយហ្វៀល អេឃ្វីបម៉ិន មេនូហ្វេកជើរីង (ខេមបូឌា) (Esastsun Oilfield Equipment Manufacturing (Cambodia) Co., Ltd.) តំណាងដោយ លោកស្រី ZHANG YI សញ្ជាតិចិន អាយុ៤១ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G22576155 ចុះថ្ងៃទី២៥ ខែ[illegible] ឆ្នាំ២០១៣ មានអាសយដ្ឋានបច្ចុប្បន្ន៖ Rm 1# 2701, Xiang Shan Garden, Wuxi, China. ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
|---|---|
| ដែកបំពង់ | ២៤១០ |

**ផ្លាកឈ្មោះរោងចក្រ៖** *" រោងចក្រកែច្នៃដែក (ដែកបំពង់) អ៊ីសាសស៊ិន អយហ្គៀល អេឃ្វីបម៉ិន មេនូហ្វេកជើរីង (ខេមបូឌា)"*

**ទីតាំងរោងចក្រ៖** *" តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (ភូមិពូធឿង ឃុំបិតត្រាំង និងភូមិស្ទាក់ដែង ឃុំរាម ស្រុកព្រៃនប់) ខេត្តព្រះសីហនុ "*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងគម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណាផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ស្តីពី ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងរាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនត្រូវបានជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរឆ្លើនទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃយ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ នឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព០៣ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ។

ខ.ម្ចាស់រោងចក្រ បានផ្តល់ជូនក្រសួងបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ របាយការណ៍ និងផលិតកម្ម ប្រចាំខែ ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់។

គ.ម្ចាស់រោងចក្រ បានបង់កម្រៃសេវាវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែង សមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំបន្តសុពលភាពទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទម្រង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែនីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេល នៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណី ខកខានក្នុងការផ្តល់ទិន្នន័យ និងរបាយការណ៍តាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៥៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណ នៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំ អំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៥ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗ ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រះសីហនុ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែ[illegible] ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

ចម្លងជូន៖

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តព្រះសីហនុ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ០២៩៣ ឧសក.កឧ.ប្រកស.១០

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ ០០៨២/១៤ ស.ត.ស.ព ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ថិចភែក ភែកឃិជីង (ខេមបូឌា) ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៤។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន ថិចភែក ភែកឃិជីង (ខេមបូឌា) (TEXPACK PACKAGING (CAMBODIA) Ltd.) តំណាងដោយ លោក WANG BIZHONG សញ្ជាតិចិន អាយុ៥០ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G56998187 ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ មានអាសយដ្ឋានបច្ចុប្បន្ន No.11 West Qilong Road, Shiqi town Panyu, Guangzhou, China. ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ១. សម្ភារៈវេចខ្ចប់ (ពីក្រដាស) | ១៧០២ |
| ២. សម្ភារៈវេចខ្ចប់ (ពីប្លាស្ទិក) | ២២២០ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ផ្លាកឈ្មោះរោងចក្រ៖** *"រោងចក្រផលិតសម្ភារៈវេចខ្ចប់ ថិចកែក កែកឃិជីង (ខេមបូឌា)"*
**ទីតាំងរោងចក្រ៖** *"តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (ភូមិព្រៃជៀង ឃុំបិតត្រាំង និងភូមិស្មាច់ដែង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ)"*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងរាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនត្រូវបានជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ នឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព០៣ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ។

ខ.ម្ចាស់រោងចក្រ បានផ្តល់ជូនក្រសួងបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ របាយការណ៍ និងផលិតកម្ម ប្រចាំខែ ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់។

គ.ម្ចាស់រោងចក្រ បានបង់កម្រៃសេវាកម្មវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែង សមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំបន្តសុពលភាពទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទម្រង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែនីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេល នៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណី ខកខានក្នុងការផ្តល់ទិន្នន័យ និងរបាយការណ៍តាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៩៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណ នៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំ អំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាម មាត្រា៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗ ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តព្រះសីហនុ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-សាលាខេត្តព្រះសីហនុ

"ដើម្បីជូនព្រាប"

-ដូចប្រការ១៤ "ដើម្បីអនុវត្ត"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ